ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២២ លេខ ១ ខែមីនា ២០១៨ តម្លៃ ១.៥០០៛

# ការយល់ឃើញពីអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ នៅក្នុងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលកម្ពុជា

## សេចក្ដីផ្ដើម

គុណភាពសេវាថែទាំសុខភាព ជាចំណុចដ៏សំខាន់មួយ នៅក្នុងផែនការសកម្មភាពរបស់ជាតិ។ ក្រសួងសុខាភិបាល គណៈគ្រូពេទ្យកម្ពុជា សាធារណជន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើការក្នុងវិស័យសុខាភិបាល បានលើកពីក្ដីបារម្ភខ្លាំង ពីគុណភាពនៃការអប់រំបណ្ដុះបណ្ដាលផ្នែកវេជ្ជសាស្ត្រ និងគុណភាពនៃការថែទាំសុខភាពនៅក្នុងប្រទេស។ កិច្ចប្រជុំតុមូលលើគោលនយោបាយស្ដីពី អាជីពវិជ្ជាជីវវេជ្ជសាស្ត្រនៅកម្ពុជា ដែល វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា (CDRI) និង វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) បានសហការរៀបចំឡើងក្នុងខែសីហា ២០១៥ បានកំណត់ឃើញបញ្ហាប្រឈម និងដំណោះស្រាយមួយចំនួន ក្នុងការលើកកម្ពស់បៀបរបបអនុវត្តផ្នែកវេជ្ជសាស្ត្រនៅកម្ពុជា។ ក្នុងនេះមានចំណុចសំខាន់មួយគឺ ការជួយគាំទ្រដល់សាលាពេទ្យ ក្នុងការផ្ដល់លទ្ធភាពដល់សាស្ត្រាចារ្យដែលបង្រៀននៅមហាវិទ្យាល័យ ឲ្យពង្រឹងកម្មវិធីសិក្សាដែលជាប់ទាក់ទងនឹងក្រមសីលធម៌គ្រូពេទ្យ សម្រាប់យកទៅបណ្ដុះបណ្ដាលដល់អ្នកអនុវត្តជាក់ស្ដែង និងដល់និស្សិតពេទ្យអំពីក្រមសីលធម៌គ្រូពេទ្យ និង អាជីពវិជ្ជាជីវវេជ្ជសាស្ត្រ។


និស្សិតពេទ្យភាគច្រើន ចង់ធ្វើការនៅគ្លីនិក ឬមន្ទីរពេទ្យ ជាងស្ថាប័នឯកជន ភ្នំពេញ ខែធ្នូ ២០១៨

វិទ្យាស្ថាន CDRI ដោយសហការជាដៃគូជាមួយ មហាវិទ្យាល័យវេជ្ជសាស្ត្រនៃ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បានធ្វើការស្រាវជ្រាវមួយ ដើម្បីធ្វើការប៉ាន់ប្រមាណពីកម្រិតនៃការយល់ដឹងរបស់និស្សិត និងការយល់ឃើញរបស់សាស្ត្រាចារ្យស្ដីពីការអនុវត្តក្នុងអាជីពវេជ្ជសាស្ត្រ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ ការសិក្សានេះ ផ្អែកលើការសន្មតថា ស្ដង់ដាខ្ពស់នៃការអប់រំពីក្រមសីលធម៌គ្រូពេទ្យ នៅសាលាពេទ្យ វានឹងនាំឲ្យការអនុវត្តវិជ្ជាជីវវេជ្ជសាស្ត្ររបស់គ្រូពេទ្យបានល្អប្រសើរ អ្នកជំងឺទទួលបានការថែទាំល្អ និងទទួលបានលទ្ធផលល្អផ្នែកសុខភាព។ ចំណុចនេះបានបំផុសសំណួរពីរ គឺ ១) តើនិស្សិតពេទ្យមានការយល់ដឹងកម្រិតណាពីអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ? ២) តើការបង្រៀន និងការរៀនស្ដីពី ក្រមសីលធម៌គ្រូពេទ្យ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (ស.វ.ស) ប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

គម្រោងសិក្សាស្រាវជ្រាវនេះ មានគោលដៅទាក់ទាញការយកចិត្តទុកដាក់ និងផ្ដល់ធនធានផ្នែកអប់រំ សម្រាប់ឲ្យថ្នាក់ដឹកនាំមហាវិទ្យាល័យវេជ្ជសាស្ត្រ និង អ្នកអប់រំផ្នែកវេជ្ជសាស្ត្រធ្វើបច្ចុប្បន្នភាព កម្មវិធីសិក្សាអំពី ក្រមសីលធម៌គ្រូពេទ្យ។

## មាតិកា

ការយល់ឃើញពីអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ នៅក្នុងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលកម្ពុជា ........................ ១
តំបន់សេដ្ឋកិច្ចពិសេស ជាឧបករណ៍សម្រាប់ពន្លឿនកំណើនសេដ្ឋកិច្ច៖ ការសិក្សាលើឯកសារ........................ ៧
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ..................... ១២
— ស្ថានភាពក្នុងប្រទេស..................... ១៥
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................................ ២៤

---

អត្ថបទនេះរៀបចំឡើងដោយ វេជ្ជបណ្ឌិត ឈឹម សារ៉ាត, អ្នកស្រាវជ្រាវផ្នែកសុខាភិបាល នៅ CDRI ព្រមទាំងជាអ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ សូមយោងអត្ថបទនេះថា៖ Chim Sarath. 2018. Perception of Medical Professionalism at the University of Health Sciences, Cambodia.” *Cambodia Development Review* 22 (1): 1–6. This project was funded by GlaxoSmithKline (Cambodia) Co., Ltd.

គោលបំណងទូទៅនៃការសិក្សានេះ គឺដើម្បីលើកកម្ពស់ចំណេះដឹង និងអាកប្បកិរិយាពាក់ព័ន្ធនឹង ក្រមសីលធម៌គ្រូពេទ្យរបស់និស្សិតនៅ ស.វ.ស.។ គោលបំណងជាក់លាក់ គឺមាន ១) ប៉ាន់ប្រមាណពី ចំណេះដឹង និងអាកប្បកិរិយារបស់និស្សិតពេទ្យ ទាក់ទងនឹងសីលធម៌គ្រូពេទ្យ ២) កំណត់ពីការយល់ឃើញ និងបទពិសោធន៍របស់សាស្ត្រាចារ្យផ្នែកវេជ្ជសាស្ត្រ ទាក់ទងនឹងការបង្រៀនមុខវិជ្ជាក្រមសីលធម៌គ្រូពេទ្យ។ អត្ថបទនេះសង្ខេបពី លទ្ធផលរកឃើញផ្សេងៗដែលអាចយកទៅប្រើការជាជំនួយសម្រាប់ការអប់រំ ដើម្បីក្រើនរំលឹកនិស្សិតពេទ្យពី កាតព្វកិច្ចរបស់ខ្លួនលើសុខភាពរបស់ប្រជាជន។

## សាវតារ

កម្ពុជា បានប្រឹងប្រែងជាខ្លាំងធ្វើការកែទម្រង់ផ្សេងៗក្នុងវិស័យសុខាភិបាល តាំងពីពាក់កណ្ដាលទសវត្សរ៍១៩៩០ មក។ លទ្ធផលនៃកំណែទម្រង់ប្រព័ន្ធសុខាភិបាល និងស្ថានភាពសុខភាពរបស់ប្រជាជន បានល្អប្រសើរឡើងយ៉ាងច្រើន។ កម្ពុជាក៏អនុវត្តបានសម្រេចឬបានលើសពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ភាគច្រើនរបស់ខ្លួន ដែលជាប់ទាក់ទងនឹងវិស័យសុខាភិបាលដែរ។ ដោយបានឈានទៅមុខគួរឲ្យកោតសរសើរ ក្នុងការញ៉ាំងឲ្យមានការគ្របដណ្ដប់នៃ សេវាថែទាំសុខភាពជាសកល និងការពង្រីកលទ្ធភាពក្នុងការទទួលបានសេវាកម្មដ៏ចាំបាច់ផ្សេងៗ គោលនយោបាយនៃការថែទាំសុខភាពសព្វថ្ងៃ បានបែរទៅផ្ដោតលើគុណភាព ដោយមានការយកចិត្តទុកដាក់កាន់តែខ្លាំងដល់ការអប់រំបណ្ដុះបណ្ដាលនិស្សិតពេទ្យ និងរបៀបរបបនៃការអនុវត្តផ្នែកវេជ្ជសាស្ត្រ។

ដោយបានដឹងពី ការធ្លាក់ចុះទំនុកចិត្តរបស់សាធារណជនទៅលើប្រព័ន្ធថែទាំសុខភាពនៅកម្ពុជា ក្រសួងសុខាភិបាលបានដាក់ចេញនូវ វិធានការជាច្រើនដើម្បីកែលំអគុណភាព និងបង្កើនគណនេយ្យភាពរបស់ស្ថាប័ន និងបុគ្គលអ្នកអនុវត្តជាក់ស្ដែង។ វិធានការទាំងនោះរួមមានផែនការយុទ្ធសាស្ត្រសុខាភិបាលជំហានទី៣ ឆ្នាំ២០១៦-២០ និង យុទ្ធសាស្ត្រសហប្រតិបត្តិការរវាងអង្គការសុខភាពពិភពលោក-កម្ពុជា (WHO 2016)។ ចំណាយសាធារណៈផ្នែកសុខាភិបាល ក៏បានកើនឡើងដែរ។ នៅឆ្នាំ២០១៦ មានការចេញព្រះរាជក្រឹត្យថ្មីមួយស្ដីពីការអនុវត្តច្បាប់វិជ្ជាជីវៈពេទ្យ។ ព្រះរាជក្រឹត្យនេះជាជំហានដ៏សំខាន់មួយសំដៅពង្រឹងរបៀបរបបអនុវត្តផ្នែកវេជ្ជសាស្ត្រឲ្យបានល្អ ក្នុងពេលដែលគ្រូពេទ្យមួយចំនួននៅកម្ពុជា កំពុងទទួលឥទ្ធិពលពីផលប្រយោជន៍ហិរញ្ញវត្ថុ។ បន្ទាប់មកទៀត គណៈគ្រូពេទ្យកម្ពុជា បានកសាងក្របខ័ណ្ឌច្បាប់មួយដើម្បីពង្រឹងបទបញ្ញត្តិក្នុងវិជ្ជាជីវៈពេទ្យ។

ការអប់រំក្រមសីលធម៌នៅសាលាពេទ្យ និងការជម្រុញការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ ដោយអង្គភាពគ្រប់គ្រងផ្នែកវេជ្ជសាស្ត្រនានា គួរធានាបាននូវរបៀបរបបអនុវត្តយ៉ាងត្រឹមត្រូវផ្នែកវេជ្ជសាស្ត្រ និងអាកប្បកិរិយាតាមស្តង់ដាល្អមួយ ដែលអាចរក្សាបាននូវទំនុកចិត្តរបស់សាធារណជនទៅលើ គ្រូពេទ្យ និងសេវាថែទាំសុខភាព។ ប៉ុន្តែការសិក្សាស្ដីពី ឥរិយាបថក្នុងការស្វែងរកសេវាថែទាំសុខភាពនៅកម្ពុជា ឲ្យលទ្ធផលផ្ទុយទៅវិញ ព្រោះថា អ្នកជ្រើសយកវិស័យឯកជន មានបីដងច្រើនជាងអ្នកជ្រើសយកវិស័យសាធារណៈ (៦៧% ទល់នឹង ២២%) សម្រាប់ការស្វែងរកសេវាព្យាបាលនៅលើកដំបូង បើយោងតាម អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១៤ (NIS 2015)។[១] របាយការណ៍ផ្សេងៗបានបង្ហាញថាប្រជាជនកម្ពុជាច្រើនសែននាក់ បានស្វែងរកការពិនិត្យសុខភាព និងការព្យាបាល ក្នុងនោះមានទាំងការសង្គ្រោះបន្ទាន់ផង នៅឯប្រទេសថៃ វៀតណាម ឬ សិង្ហបុរី។ ក្នុងចំណោមទេសចរកម្ពុជាដែលចេញទៅស្វែងរក សេវាថែទាំសុខភាពនៅក្រៅប្រទេសក្នុងឆ្នាំ២០១៦ មាន ២៤% (៣៣៦.០០០នាក់) បានទៅថៃ នឹង ៣០% (៤២០.០០០នាក់) បានទៅវៀតណាម (AKP 2017 cited in Marady and Huaifu 2017, 2)។ យោងតាមឯកសារយុទ្ធសាស្ត្រនៃ កិច្ចសហប្រតិបត្តិការរវាងអង្គការសុខភាពពិភពលោក-កម្ពុជា កង្វះបុគ្គលិកសុខាភិបាលប្រកបដោយគុណភាព និងទឹកចិត្តស្រួចស្រាវ ទាំងក្នុងវិស័យសាធារណៈ និងឯកជន បានចោទបញ្ហាបន្ថែមដល់ការផ្ដល់សេវាថែទាំសុខភាពមានគុណភាពល្អអាចទទួលយកបាន (WHO 2016, 20)។

អាជីពវិជ្ជាជីវៈរបស់អ្នកអនុវត្តផ្នែកវេជ្ជសាស្ត្រ បង្កើតបានជាកិច្ចសន្យាជាមូលដ្ឋានរវាងគ្រូពេទ្យនឹងសង្គម។ Cruess (2006, 170) បានពិពណ៌នាថាជាកិច្ចសន្យាសង្គមមួយដែលក្នុងនោះ "ការរំពឹងទុករបស់សង្គមទៅលើជំនាញវេជ្ជសាស្ត្រ គឺមាន សេវារបស់អ្នកព្យាបាលដែលមានសមត្ថភាពច្បាស់លាស់ ចេះគិតគូរយកចិត្តទុកដាក់ដល់ប្រយោជន៍អ្នកដទៃ ជាងផលប្រយោជន៍ផ្ទាល់ខ្លួន មានសីលធម៌ល្អ មានភាពសុចរិត មានគណនេយ្យភាព តម្លាភាព ផ្ដល់មតិណែនាំមានហេតុផលត្រឹមត្រូវ និង លើកកម្ពស់ផលប្រយោជន៍របស់សាធារណជន"។ ការឃ្លាតចាកគួរឲ្យកត់សំគាល់ពីក្រមសីលធម៌ក្នុងការអនុវត្តកិច្ចសន្យានេះនៅកម្ពុជា បានក្លាយជាក្ដីបារម្ភធំមួយសម្រាប់អ្នកអនុវត្តការងារពេទ្យ អ្នកកសាងគោលនយោបាយ និងជាពិសេសសាធារណជន។ វាគូសបញ្ជាក់ពីសារៈសំខាន់និងភាពចំពេលល្អនៃ ការស្រាវជ្រាវនេះដែលបង្ហាញលទ្ធផលថា ការពិនិត្យឡើងវិញ និងការកែលំអ ក្រមសីលធម៌គ្រូពេទ្យនៅតាមសាលាពេទ្យកម្ពុជា នឹងជួយលើកកម្ពស់ការគោរពតាមក្រមសីលធម៌និងវិជ្ជាជីវៈពីសំណាក់និស្សិតពេទ្យ និងធានាបាននូវស្តង់ដារួមមួយសម្រាប់ការចូលទៅក្នុងអាជីពវេជ្ជសាស្ត្រ។

## គោលគំនិតនៃអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ

អាជីពវិជ្ជាជីវវេជ្ជសាស្ត្រ មាននិយមន័យខុសៗគ្នានៅក្នុងឯកសារមានស្រាប់ផ្សេងៗ (see, for example, Passi et al. 2010; Tallis 2006) និងដែលអាចសង្ខេបបានថាជា "គ្រឹះនៃទំនុកចិត្តដែលនៅលើនោះ គេត្រូវកសាងទំនាក់ទំនងរវាងគ្រូពេទ្យនឹងអ្នកជំងឺ" (Ahadi et al. 2015, Abstract) ហើយ "នៅក្នុងវិជ្ជាជីវៈពេទ្យ គ្រូពេទ្យត្រូវបម្រើផលប្រយោជន៍របស់អ្នកជំងឺលើសពីផលប្រយោជន៍របស់ខ្លួនផ្ទាល់ (ABIM 2995,5) (ABIM 1995,5)។ ជាក់លាក់ជាងនេះទៅទៀត "អាជីពវិជ្ជាជីវវេជ្ជសាស្ត្រមានរាប់បញ្ចូល ការចេះគិតគូរយកចិត្តទុកដាក់ដល់ផលប្រយោជន៍

[១] ផ្អែកលើសំណាកអ្នកជំងឺ និងអ្នករបួស ៩.៦៥៦នាក់ (៧.៩០២នាក់នៅទីក្រុង និង ១.៧៥៥នាក់នៅជនបទ) ដែលស្វែងរកការព្យាបាល។

តារាង១៖ លក្ខណៈស្នូលនៃអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ ដូចមានកំណត់ជាទូទៅនៅក្នុងឯកសារនានា

| ABIM 1995 | Tallis 2006 | Mueller 2009 | ACGME 2007 | Mueller 2015 |
|---|---|---|---|---|
| • ការគិតគូរដល់អ្នកដទៃ<br>• គណនេយ្យភាព<br>• ភាពល្អវិសេស<br>• ភារកិច្ច<br>• កិត្តិយស<br>• ភាពសុចរិត<br>• ការគោរពអ្នកដទៃ | • ការគិតគូរដល់អ្នកដទៃ<br>• ភាពល្អវិសេស<br>• ការងារជាក្រុម<br>• ភាពសុចរិត<br>• មេត្តាធម៌<br>• ការកែលំអជាប្រចាំ | • ការគិតគូរដល់អ្នកដទៃ<br>• គណនេយ្យភាព<br>• ភាពល្អវិសេស<br>• ភាពសុចរិត<br>• មេត្តាធម៌<br>• ការយល់ចិត្ត<br>• ក្រមសីលធម៌ពេទ្យល្អ<br>• ការប្រស្រ័យទាក់ទង មានប្រសិទ្ធភាព<br>• សមត្ថភាពព្យាបាល | • ការគិតគូរដល់អ្នកដទៃ<br>• គណនេយ្យភាព<br>• ភាពល្អវិសេស<br>• ភាពសុចរិត<br>• ការគោរពអ្នកដទៃ<br>• មេត្តាធម៌<br>• ក្រមសីលធម៌ល្អ<br>• ភាពឆ្លើយតប<br>• ការគិតគូរពីភាពចម្រុះបែប | • ការគិតគូរដល់អ្នកដទៃ<br>• គណនេយ្យភាព<br>• ភាពល្អវិសេស<br>• មនុស្សធម៌<br>• ក្រមសីលធម៌ពេទ្យល្អ<br>• ការប្រស្រ័យទាក់ទងមានប្រសិទ្ធភាព<br>• សមត្ថភាពព្យាបាល |

អ្នកដទៃជាងផលប្រយោជន៍ផ្ទាល់ខ្លួន គណនេយ្យភាព ការអនុវត្តឲ្យបានល្អប្រសើរ ការបំពេញតាមកាតព្វកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ សេវាប្រកបដោយគុណភាព ភាពសុចរិត ការផ្ដល់កិត្តិយស និងការគោរពដល់អ្នកដទៃ" (ABIM 1995, 5)។

ទស្សនៈស្រដៀងគ្នានេះ មានលើកឡើងនៅក្នុងឯកសាររបស់ Tallis (2006), Mueller (2009) និង ក្រុមប្រឹក្សាបញ្ជាក់គុណភាពសម្រាប់ ឧត្តមសិក្សាផ្នែកវេជ្ជសាស្ត្រ (ACGME 2007)[២] ដូចមានបង្ហាញក្នុង តារាង១។ លក្ខន្តិកៈគ្រូពេទ្យ ដែលជាការងាររួមគ្នារបស់ ក្រុមប្រឹក្សាគ្រូពេទ្យរបស់សហរដ្ឋអាមេរិក និងអឺរ៉ុប (ABIM, ACP- ASIM and EFIM 2002) បានកំណត់នូវគោលការណ៍មូលដ្ឋានចំនួន៣ និងទំនួលខុសត្រូវវិជ្ជាជីវៈចំនួន១០ (តារាង២)។ លក្ខណៈទាំងអស់នេះនៃអាជីពវិជ្ជាជីវវេជ្ជសាស្ត្រក្រោយមក ក៏មានប្រទេសជាច្រើនលើសកលលោកអនុម័តប្រើដែរ។ ក្រុមប្រឹក្សាសហរដ្ឋអាមេរិកនៃវេជ្ជសាស្ត្រក្នុងស្រុក (ABIM 1995, 6-9) បានពិពណ៌នាពី សញ្ញានិងរោគសញ្ញា ចំនួន៧ នៃភាពខ្វះអាជីពវិជ្ជាជីវៈដែលធ្វើឲ្យចុះខ្សោយដល់ សមាសធាតុស្នូលនៃអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ (តារាង៣)។ ក្រុមប្រឹក្សាសហរដ្ឋអាមេរិកផ្នែកវេជ្ជសាស្ត្រក្នុងស្រុក (ABIM) បានសង្កត់ធ្ងន់ថា អាកប្បកិរិយាខ្វះអាជីពវិជ្ជាជីវៈ ឬគ្មានសីលធម៌ទាំងនេះ នាំឲ្យវេចរឹលខូចខាតដល់ទំនុកចិត្តរបស់សាធារណជន និងរំលោភលើស្តង់ដានៃការគោរពតាមក្រមសីលធម៌។

នៅកម្ពុជា សមាសធាតុទាំងអស់នេះនៃ អាជីពវិជ្ជាជីវវេជ្ជសាស្ត្រ មានចែងនៅក្នុង អនុក្រឹត្យស្ដីពី ក្រមសីលធម៌គ្រូពេទ្យ (RGC 2003) ព្រមទាំងក្នុង សម្បថរបស់អ្នកប្រកបវិជ្ជាជីវពេទ្យ អ៊ីប៉ូក្រាត ដែលនិស្សិតពេទ្យទាំងអស់ត្រូវធ្វើការស្បថសច្ចានៅមុនពេលចាប់ផ្ដើមការសិក្សា និងដែលវេជ្ជបណ្ឌិតកម្ពុជាទើបទទួលបានសញ្ញាប័ត្រត្រូវធ្វើឡើង នៅពេលចុះបញ្ជីជាគ្រូពេទ្យ (RGC n.d.)។

តារាង២៖ លក្ខន្តិកៈគ្រូពេទ្យស្ដីពីអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ

**គោលការណ៍គ្រឹះ**

១. សុខមាលភាពអ្នកជំងឺជាចម្បង
២. ស្វ័យភាពអ្នកជំងឺ
៣. យុត្តិធម៌សង្គម

**ទំនួលខុសត្រូវក្នុងវិជ្ជាជីវៈ**

ការប្ដេជ្ញាចិត្តលើ៖
១. សមត្ថភាពវិជ្ជាជីវៈពេញលេញ
២. ភាពស្មោះត្រង់ជាមួយអ្នកជំងឺ
៣. ការរក្សាការសំងាត់របស់អ្នកជំងឺ
៤. ការរក្សាទំនាក់ទំនងសមស្របជាមួយអ្នកជំងឺ
៥. ការកែលំអនិងលើកកម្ពស់គុណភាពនៃការថែទាំ
៦. ការលើកកម្ពស់ការទទួលបានសេវាថែទាំ
៧. ការបែងចែកដោយយុត្តិធម៌នូវធនធានមានកំណត់
៨. ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ
៩. ការរក្សាទំនុកចិត្តតាមការគ្រប់គ្រងទំនាស់ផលប្រយោជន៍
១០. ទំនួលខុសត្រូវក្នុងវិជ្ជាជីវៈ

ប្រភព: Mueller 2015

តារាង៣៖ សញ្ញានិងរោគសញ្ញាទាំង ៧ នៃភាពមិនវិជ្ជាជីវៈ

• ការរំលោភអំណាច
(ឧ. ភាពលំអៀង ការរំខានផ្លូវភេទ ការរំលោភលើការសំងាត់)
• ភាពក្រអឺតក្រទមក្នុងវិជ្ជាជីវៈ
• ការលោភលន់
• ការលើកបង្ហាញមិនត្រឹមត្រូវ (ឧ. ការភូតភរ ឬក្លែងបន្លំ)
• ការចុះខ្សោយ (ឧ. សុខភាពផ្លូវចិត្ត)
• កង្វះស្មារតីភ្ញាក់រលឹក
• ទំនាស់ផលប្រយោជន៍
(ឧ. ការបញ្ជូនអ្នកជំងឺទៅគ្លីនិករបស់ខ្លួន ការទទួលជំនូន)

ប្រភព: ABIM 1995

[២] ក្រុមប្រឹក្សាបញ្ជាក់គុណភាពសម្រាប់ឧត្តមសិក្សាផ្នែកវេជ្ជសាស្ត្រ (ACGME 2007) របស់សហរដ្ឋអាមេរិក គឺជា អង្គការឯកជន មិនស្វែងរកចំណេញ ដឹកនាំដោយគ្រូពេទ្យ ដែលកំណត់និងឃ្លាំមើល ស្តង់ដាអប់រំវិជ្ជាជីវៈដ៏ចាំបាច់សម្រាប់ត្រៀមរៀបចំគ្រូពេទ្យឲ្យផ្ដល់ការថែទាំផ្នែកវេជ្ជសាស្ត្រ មានសុវត្ថិភាព និងគុណភាពខ្ពស់ ដល់ប្រជាជនសហរដ្ឋអាមេរិកគ្រប់ៗគ្នា។

## វិធីសាស្ត្រ និងការវិភាគទិន្នន័យ

ការសិក្សានេះប្រើវិធីសាស្ត្រចម្រុះ ដោយគួបផ្សំការវិភាគទិន្នន័យបែបគុណវិស័យ និងបែបបរិមាណវិស័យ។ ការប្រមូលទិន្នន័យតាមវិធីសាស្ត្រទាំងពីរនេះ បានធ្វើឡើងតំណាលគ្នា ចាប់តាំងពីខែធ្នូ ២០១៧ ដល់ មករា ២០១៨ នៅក្នុងមហាវិទ្យាល័យវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) នៅក្រុងភ្នំពេញ។

ការប្រមូលទិន្នន័យបែបគុណវិស័យ ត្រូវបានធ្វើឡើងតាមរយៈ ការធ្វើសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) ចំនួន ២៣នាក់ ដែលមានជាអាទិ៍ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង តំណាងគណៈគ្រូពេទ្យកម្ពុជា និងសាស្ត្រាចារ្យ តាមមុខវិជ្ជាផ្សេងៗ ដូចជា ខាង រោគស្ត្រីនិងសម្ភព វេជ្ជសាស្ត្រទូទៅ ការវះកាត់ ជំងឺកុមារ និងក្រមសីលធម៌គ្រូពេទ្យ។ ការធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ មានគោលដៅដើម្បីក្តាប់យកព័ត៌មានពីការយល់ឃើញ និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ស្តីពីប្រព័ន្ធថែទាំសុខភាពកម្ពុជា និងការបង្រៀនពីក្រមសីលធម៌គ្រូពេទ្យនៅ មហាវិទ្យាល័យវេជ្ជសាស្ត្រ នៃសាកលវិទ្យាសាស្ត្រសុខាភិបាល ។

ការប្រមូលទិន្នន័យបែបបរិមាណវិស័យ ត្រូវបានធ្វើឡើងតាមរយៈការធ្វើសម្ភាសន៍ជាមួយនិស្សិតឆ្នាំទី៥ ចំនួន ១១០នាក់ និង និស្សិតឆ្នាំទី៦ ចំនួន១២៦នាក់ (សរុប ២៣៦នាក់) ជ្រើសរើសឡើងដោយចៃដន្យចេញពីចំនួននិស្សិតសរុប ៦២៥នាក់ (៣១៩នាក់ឆ្នាំទី៥ និង ៣០៦នាក់ឆ្នាំទី៦)។ និស្សិតឆ្នាំទី៥ មិនទាន់បានចូលវគ្គសិក្សាពីក្រមសីលធម៌គ្រូពេទ្យទេ រីឯនិស្សិតឆ្នាំទី៦ បានបញ្ចប់វគ្គនេះហើយ។

កម្រងសំណួរអង្កេតដែលមានសំណួរ និង ២២ ពាក្យអះអាង ដែលត្រូវបានតាក់តែងឡើងដើម្បីវាស់ស្ទង់ពីកម្រិតនៃការយល់ដឹងអំពីអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ ដោយប្រើខ្នាតរបស់ Likert មាន ៥ពិន្ទុ។ អ្នកចូលរួមត្រូវបានស្នើឲ្យបញ្ជាក់ពីកម្រិតនៃការយល់ស្រប ឬមិនយល់ស្របទៅនឹងពាក្យអះអាងនីមួយៗ ដោយប្រើចំណាត់ថ្នាក់ដូចខាងក្រោម៖ ១=មិនយល់ស្របទាល់តែសោះ ២=មិនយល់ស្រប ៣=មិនច្បាស់លាស់ ៤=យល់ស្រប ៥=យល់ស្របទាំងស្រុង។

កម្រងសំណួរអង្កេត និងសំណួរសម្ភាសន៍ បានតាក់តែងឡើងដោយផ្អែកលើការសិក្សាឯកសារវិទ្យាសាស្ត្រ ស្តីពីសមាសធាតុស្នូលនៃអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ ដូចជា ការគិតគូរដល់ផលប្រយោជន៍អ្នកដទៃជាងផលប្រយោជន៍ផ្ទាល់ខ្លួន ការប្រស្រ័យទាក់ទង ការសម្រេចផ្អែកបច្ចេកទេសឲ្យបានល្អបំផុត ការគោរពស្វ័យភាពរបស់អ្នកជំងឺ ការបំពេញតាមភារកិច្ច ចិត្តល្អ ការជៀសវាងបង្កគ្រោះថ្នាក់ និងការឈឺចាប់ដល់អ្នកជំងឺ ការមានគណនេយ្យភាព មានទំនួលខុសត្រូវក្នុងវិជ្ជាជីវៈ មានការគោរពមានយុត្តិធម៌ មានការស្វ័យកែលំអខ្លួន និង ការសម្របខ្លួន។ សម្រាប់ភាពខ្វះវិជ្ជាជីវៈ កម្រងសំណួរមានការផ្តោតជាសំខាន់ទៅលើកម្រិតនៃការយល់ស្រប ឬមិនយល់ស្របតាម ពាក្យអះអាងដើម្បីវាយតម្លៃលើការយល់ដឹងរបស់និស្សិតអំពី ទំនាស់ផលប្រយោជន៍។

ការវិភាគតាមប្រធានបទ ត្រូវបានអនុវត្តទៅលើកំណត់ត្រាដែលបានពីការធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ ដើម្បីទទួលបាននូវអត្ថន័យគ្រប់ជ្រុងជ្រោយអំពី ចំណាប់អារម្មណ៍ និង ការយល់ឃើញរបស់អ្នកផ្តល់ព័ត៌មានគន្លឹះ។ ស្ថិតិបែបពិពណ៌នាត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពីលក្ខណៈរបស់និស្សិត និង ដើម្បីកំណត់នូវប្រេកង់ និងរបាយនៃចម្លើយ។ តេស្តខាយស្វែ (Chi-square test) ត្រូវបានយកមកប្រើដើម្បីកំណត់ថា តើភាពខុសគ្នានៃរបាយចម្លើយរបស់ និស្សិតឆ្នាំទី៥ និង និស្សិតឆ្នាំទី៦ គួរឲ្យជឿបានដែរឬទេ។

## លទ្ធផលរកឃើញ

### *ការយល់ឃើញរបស់និស្សិតពីក្រមសីលធម៌គ្រូពេទ្យ*

តបនឹងសំណួរអំពីចំណង់ធ្វើការ និស្សិត ៩៥% ឆ្លើយថា ពួកគាត់ចង់ធ្វើការនៅគ្លីនិក ឬមន្ទីរពេទ្យ ជាជាងធ្វើការងារខាងសុខភាពសាធារណៈ ឬការងារគ្រប់គ្រង។ ស្រដៀងគ្នាដែរ និស្សិត ៩៥% ចង់ធ្វើការក្នុងរដ្ឋាភិបាល ជាជាងក្នុងវិស័យឯកជន។ ទាក់ទងនឹងក្រមសីលធម៌គ្រូពេទ្យ និស្សិតឆ្នាំទី៥ និង ឆ្នាំទី៦ បានបង្ហាញនូវកម្រិតនៃការយល់ដឹងប្រហាក់ប្រហែលគ្នា។

តារាង៤ ផ្តល់នូវ របាយពិន្ទុមធ្យមសរុបសម្រាប់ចម្លើយលើពាក្យអះអាងទាំង ២២ គឺស្ថិតក្នុងចន្លោះពី ៧៧ ទៅ ១០៧ (ធៀបនឹង តម្លៃអប្បបរមា-អតិបរមា ពី ២២ ទៅ ១១០)។ ផលបូកនៃពិន្ទុចម្លើយរបស់និស្សិតបង្ហាញថា ២៥% ស្ថិតក្នុងចន្លោះពី ៧៧ ទៅ ៨៨ ដែលបង្ហាញនូវកម្រិតយល់ដឹងទាប ចំពោះអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ ចំណែកឯនិស្សិត ៥០% បន្ទាប់មកទៀត បានពិន្ទុក្នុងចន្លោះពី ៨៩ ទៅ ៩៧ ដែលបង្ហាញពីចំណេះដឹង និងអាកប្បកិរិយាវិជ្ជមានចំពោះអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ។

តារាង៤៖ របាយពិន្ទុមធ្យមសរុប (distribution of total mean scores) សម្រាប់ចម្លើយទាំង ២២

| | គិតជាក្រុមភាគរយ (%) | | | | | មធ្យម (SD) |
|---|---|---|---|---|---|---|
| | អប្បបរមា | 25 | 50 | 75 | អតិបរមា | |
| ចំណាត់ថ្នាក់ជាមធ្យម | 77 | 88 | 93 | 97 | 107 | 92.37 (6.68) |

ចំណាំ៖ SD= គំលាតស្តង់ដា (standard deviation)

ពាក្យអះអាងចំនួន ១៦ (៧៣%) ក្នុងចំណោមពាក្យអះអាងទាំង ២២ គ្របដណ្តប់លក្ខណៈសម្បត្តិមួយចំនួន ដូចជា ការគិតគូរដល់ផលប្រយោជន៍អ្នកដទៃជាងផលប្រយោជន៍ផ្ទាល់ខ្លួន ការគោរពគណនេយ្យភាពការបំពេញតាមភារកិច្ចការគោរពស្វ័យភាពរបស់អ្នកជំងឺ ការប្រស្រ័យទាក់ទង និងការសម្រេចផ្អែកបច្ចេកទេសឲ្យបានល្អបំផុត។ សម្រាប់ ១៦ពាក្យអះអាងនេះ ពិន្ទុមធ្យមក្នុងចន្លោះពី ៤,០០ ទៅ ៤,៩៨ (គិតលើ ៥) គឺបង្ហាញថា និស្សិតមានការយល់ដឹងខ្ពស់។ ផ្ទុយទៅវិញ ពិន្ទុមធ្យម ៣,១ សម្រាប់ពាក្យអះអាងថា "គ្រូពេទ្យត្រូវការពារកុំឲ្យមានគ្រោះថ្នាក់ និងការឈឺចាប់ដល់អ្នកជំងឺ" និង ពិន្ទុមធ្យម ២,៧១ សម្រាប់ពាក្យអះអាងថា "និស្សិតត្រូវទទួលស្គាល់សមត្ថភាពមានកម្រិតរបស់ខ្លួន"

គឺបង្ហាញពីការយល់ដឹងកម្រិតទាប។ ពិន្ទុមធ្យមទាបជាងគេត្រឹម ២,៤៦ គឺពាក់ព័ន្ធនឹងពាក្យអះអាងពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍។ ពិន្ទុមធ្យមរបស់និស្សិត ក្នុង ៣ ចំណុចចុងក្រោយនេះ បង្ហាញពីការយល់ដឹងនៅមានកម្រិតទាប និងបង្ហាញពីចំណេះដឹងដែលខ្វះលក្ខណៈជាអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ។

ដោយឡែក ៥៤% នៃអ្នកឆ្លើយសម្ភាសន៍ បានយល់ស្រប និង យល់ស្របទាំងស្រុងថា "ក្នុងអំឡុងពេលចុះអនុវត្តផ្ទាល់ក្នុងកម្មសិក្សា និស្សិតពេទ្យត្រូវធ្វើតាមអ្វីៗទាំងអស់ដែលគ្រូពេទ្យគ្រប់គ្រងប្រាប់ឲ្យធ្វើ"។ ចំណុចនេះបង្ហាញថា និស្សិតអាចអនុវត្តនូវ វិធីសាស្ត្រថែទាំផ្សេងៗដែលខ្លួនមិនទាន់បានទទួលការបណ្តុះបណ្តាលនៅឡើយ។ សរុបមក និស្សិតមិនបានចាប់អារម្មណ៍ពីសារៈសំខាន់នៃការយល់ដឹងច្បាស់លាស់ និងការបំពេញការងារក្នុងដែនសមត្ថភាពរបស់ខ្លួន ក៏ដូចជា មិនបានប្រាប់គ្រូពេទ្យគ្រប់គ្រងអំពីកម្រិតដែនសមត្ថភាពនេះទេ។ អ្នកផ្តល់ចម្លើយ ១៧% បានយល់ស្រប និង យល់ស្របទាំងស្រុងថា "គ្រូពេទ្យមិនគួរទទួលយក កំហុស ឬការភ្លាំងភ្លាត់ ដែលគិលានុបដ្ឋាក ឬឆ្មបបានរាយការណ៍ឡើងនោះទេ"។ លទ្ធផលនេះបង្ហាញថា និស្សិតភាគច្រើនមិនទាន់យល់ច្បាស់ទេថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីសម្រួចសម្រាំង កម្រិតបច្ចេកទេសឲ្យបានល្អបំផុតនោះ។ អ្នកឆ្លើយអង្កេត ១២% បានយល់ស្រប និង យល់ស្របទាំងស្រុងថា "អ្នកប្រកបវិជ្ជាជីវពេទ្យ ត្រូវការឲ្យមានការក្រើនរំលឹកជាប្រចាំពីអ្នកមានឋានៈស្មើ និងពីអ្នកគ្រប់គ្រង លើការបំពេញភារកិច្ចនិងទំនួលខុសត្រូវចំពោះ អ្នកជំងឺ និងអ្នកប្រកបវិជ្ជាជីវពេទ្យផ្សេងទៀត"។ ចំណុចនេះមានន័យថា និស្សិតទាំងនេះមិនទាន់បានទទួលស្គាល់ពេញលេញទេនូវ អាកប្បកិរិយា និងទំនួលខុសត្រូវដែលគេរំពឹងថា ខ្លួនត្រូវប្រកាន់យកក្នុងឋានៈជាអ្នកវិជ្ជាជីវៈ។

លទ្ធផលនៃការសិក្សាបង្ហាញថា និស្សិតឆ្នាំទី៥ និង និស្សិតឆ្នាំទី៦ មានការយល់ដឹងប្រហាក់ប្រហែលគ្នា។ ចំណុចនេះបង្ហាញថា និស្សិតបានរៀនសូត្រ និងបានស្រូបយក ទាំងការអនុវត្តប្រកបដោយវិជ្ជាជីវៈ និងមិនវិជ្ជាជីវៈ តាមរយៈការសង្កេតមើល និងអនុវត្តតាមរបៀបរបបអនុវត្តរបស់គ្រូពេទ្យនៅតាមគ្លីនិក និង មន្ទីរពេទ្យនានា។ មេរៀនដែលនិស្សិតរៀនសូត្របានតាមវិធីនេះ ហៅថា ការរៀនសូត្រពីកម្មវិធីសិក្សាលាក់បង្កប់ ឬកម្មវិធីសិក្សាក្រៅផ្លូវការតាមបែបធម្មជាតិ គឺពិបាកមើលឃើញ និងពិបាកវាយតម្លៃណាស់។

## *ការយល់ឃើញរបស់សាស្ត្រាចារ្យ*

លទ្ធផលរកឃើញតាមរយៈ ការធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះមួយចំនួន បង្ហាញថា និស្សិតភាគច្រើនមិនសូវចាប់អារម្មណ៍នឹងមុខវិជ្ជាក្រមសីលធម៌គ្រូពេទ្យទេ ព្រោះពួកគាត់គិតថា វាគ្រាន់តែជាមុខវិជ្ជាអរូបីមួយ និងមិនចាំបាច់ ដូចមុខវិជ្ជាគ្លីនិកនោះទេ។ ហេតុដូច្នេះ និស្សិតមិនសូវចូលរៀនថ្នាក់ក្រមសីលធម៌គ្រូពេទ្យទេ ហើយព្យាយាមរៀនតែសំណួរ MCQ (សំណួរមានចម្លើយច្រើន) ដែលមានកំណែស្រាប់ទៅវិញ។ ម្យ៉ាងទៀត សំណួរ MCQs ដែលមានចំនួនតិច គួបផ្សំនឹង ការឃើតយ៉ាវក្នុងការដាក់បញ្ចូលមុខវិជ្ជាក្រមសីលធម៌គ្រូពេទ្យផង (គឺទាល់តែដល់ឆមាសទី២ នៃឆ្នាំទី៥) បាននាំឲ្យនិស្សិតមានការខ្វះចន្លោះនូវចំណេះដឹងជាប់ទាក់ទងនឹងក្រមសីលធម៌គ្រូពេទ្យ ធ្វើឲ្យនិស្សិតងាយចម្លងយករបៀបរបបអនុវត្តដែលប្រាសចាកពីក្រមសីលធម៌ក្នុងអំឡុងពេលពួកគាត់ចុះធ្វើកម្មសិក្សានៅតាមមន្ទីរពេទ្យ។

អ្នកផ្តល់បទសម្ភាសន៍ បានលើកពីមូលហេតុជាច្រើនដែលនាំឲ្យនិស្សិតហាក់មិនសូវចាប់អារម្មណ៍ពី មុខវិជ្ជាក្រមសីលធម៌គ្រូពេទ្យ ដូចជា ការធ្វើអត្ថាធិប្បាយពន្យល់បែបបាឋកថា គឺជាវិធីសាស្ត្របង្រៀនតែមួយគត់ និស្សិតអាចប្រឡងជាប់ក្នុងមុខវិជ្ជានេះដោយមិនចាំបាច់ទៅស្តាប់ការបង្រៀនក្នុងថ្នាក់ និស្សិតខ្លះយល់ថា ប្រធានបទនេះ មិនទាក់ទងនឹងការព្យាបាលជំងឺទេ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មិនបានផ្តល់អាទិភាពដល់មុខវិជ្ជាក្រមសីលធម៌គ្រូពេទ្យ សកម្មភាពដាក់វិន័យនៅខ្សោយចំពោះ អវត្តមានក្នុងមុខវិជ្ជាក្រមសីលធម៌គ្រូពេទ្យ ហើយនិស្សិតរៀនត្រឹមតែឲ្យប្រឡងជាប់តែប៉ុណ្ណោះ។

សាស្ត្រាចារ្យមិនបានបង្ហាញឲ្យបានច្បាស់លាស់ទេ នូវទិដ្ឋភាពនៃភាពគ្មានវិជ្ជាជីវៈ (unprofessionalism) លើកលែងតែទំនាស់ផលប្រយោជន៍ ដោយសាស្ត្រាចារ្យមួយចំនួនបាននិយាយថា គ្រូពេទ្យអាចទទួលយកបាននូវជំនូន និងអំណោយ (ឧ. ជាប្រាក់កាស ចំណីអាហារ បង្អែម ផ្លែឈើ ភេសជ្ជៈ) ដែលអ្នកជំងឺ ឬក្រុមគ្រួសារអ្នកជំងឺផ្តល់ឲ្យដោយស្ម័គ្រចិត្ត ជាថ្នូរនឹងការផ្តល់សេវារបស់បុគ្គលិកពេទ្យ ព្រោះសាស្ត្រាចារ្យទាំងនោះយល់ថា វាជាវប្បធម៌នៃការជូន របស់កម្ពុជា។

## សេចក្តីសន្និដ្ឋាន

ភាគច្រើននៃនិស្សិតឆ្នាំទី៥ និងឆ្នាំទី៦ នៅ ស.វ.ស. មានការយល់ដឹងពីគោលគំនិត និងរបៀបរបបអនុវត្តក្នុងអាជីពវិជ្ជាជីវវេជ្ជសាស្ត្រ។ មាន ៤ចំណុច ដែលនិស្សិតទាំងពីរថ្នាក់ទទួលបានពិន្ទុទាប គឺគ្រូពេទ្យត្រូវការពារកុំឲ្យមានគ្រោះថ្នាក់ និងការឈឺចាប់ដល់អ្នកជំងឺ ការប្រស្រ័យទាក់ទងរវាងគ្រូពេទ្យជាមួយអ្នកជំងឺនិងក្រុមគ្រួសារអ្នកជំងឺ ទំនួលខុសត្រូវក្នុងការបំពេញតួនាទីវិជ្ជាជីវៈនិងការមិនចង់ទទួលយកការទិតៀនបែបស្ថាបនា (ជំហរនេះផ្ទុយនឹងគោលការណ៍នៃការប្រឹងប្រែងកែលំអខ្លួន និងការសម្របខ្លួន)។

លទ្ធផលសិក្សាបានបង្ហាញនូវ ការយល់ច្រឡំក្នុងចំណោមនិស្សិត និងសាស្ត្រាចារ្យមួយចំនួន អំពីខ្លឹមសារនៃទំនាស់ផលប្រយោជន៍។ អ្នកទាំងនោះយល់ថា អំណោយផ្សេងៗដែលក្រុមហ៊ុនឱសថផ្តល់ទៅឲ្យអ្នកផ្តល់សេវាថែទាំសុខភាព និងការបង់ប្រាក់ក្រៅផ្លូវការរបស់អ្នកជម្ងឺ នៅតាមមន្ទីរពេទ្យសាធារណៈ វាជារឿងធម្មតា និងអាចទទួលយកបាន គឺមិនមែនជាទង្វើខុសនឹងក្រមសីលធម៌វិជ្ជាជីវៈនោះទេ។ បញ្ហាទាក់ទងនឹង ទំនាស់ផលប្រយោជន៍ទាំងនេះ អាចធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ និងកិត្តិស័ព្ទរបស់គ្រូពេទ្យ និងធ្វើឲ្យសាធារណជនបាត់បង់ទំនុកចិត្ត ទៅលើសេវាថែទាំសុខភាព ហើយគួរតែមានវិធានការទប់ស្កាត់ឲ្យបានម៉ឺងម៉ាត់។ ការប្តេជ្ញាចិត្តក្នុងការពង្រឹងក្រមសីលធម៌គ្រូពេទ្យឡើងវិញ នឹងជួយជួសជុលពង្រឹងទំនុកចិត្តរបស់សាធារណជនទៅលើអាជីពវិជ្ជាជីវពេទ្យ។

វាជារឿងគួរឲ្យព្រួយបារម្ភធំមួយ ព្រោះលទ្ធផលសិក្សាបានបង្ហាញពី ការយល់ឃើញរបស់និស្សិតភាគច្រើនដែលថា ការបង្កគ្រោះថ្នាក់ និងការឈឺចាប់ដល់អ្នកជំងឺ គឺជារឿងធម្មតា និងអាចទទួលយកបាន។ ការយល់ឃើញបែបនេះបង្ហាញថា ទៅអនាគតនៅពេលក្លាយខ្លួនទៅជាវេជ្ជបណ្ឌិត គ្រូពេទ្យ ពួកគាត់អាចធ្វើការដោយខ្ជីខ្ជា ជាពិសេស បើសិនជាមានជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ពួកគាត់នឹងអាចបង្កឲ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ដល់អ្នកជំងឺ។

និស្សិតភាគច្រើនបានបង្ហាញនូវ កង្វះការប្រឹងប្រែងកែលំអខ្លួន និងសម្របខ្លួន ដោយសារពួកគេមិនបានដឹងពីចំណុចខ្វះខាតរបស់ខ្លួន។ ជាគោលការណ៍ និស្សិតពេទ្យត្រូវមានលទ្ធភាពទទួលស្គាល់ និងអនុវត្តការងារថែទាំ និងព្យាបាលជំងឺក្នុងដែនសមត្ថភាពរបស់ខ្លួន។ ការមិនបានធ្វើដូច្នេះ វាបង្ហាញនូវការមិនបានបំពេញតាមភារកិច្ច និងទំនួលខុសត្រូវក្នុងវិជ្ជាជីវៈ គឺមានន័យថា និស្សិតបំពេញមិនបានតាមស្តង់ដានៃ អាកប្បកិរិយាក្នុងវិជ្ជាជីវៈដែលគេរំពឹងថាខ្លួនធ្វើបាននោះឡើយ។

បញ្ហានាំឲ្យភាន់ច្រឡំមួយទៀត គឺនិស្សិតហាក់ដូចរៀនសូត្របានយ៉ាងច្រើនពីកម្មវិធីសិក្សាក្រៅផ្លូវការ ដែលទំនងជាដើរតួនាទីសំខាន់ក្នុងការពង្រឹងអាកប្បកិរិយា និងឥរិយាបថចំពោះអាជីពវិជ្ជាជីវវេជ្ជសាស្រ្ត។ បញ្ហានេះបង្ហាញថា របៀបបង្រៀនពីក្រមសីលធម៌វិជ្ជាជីវៈត្រូវតែពិនិត្យឡើងវិញ ដើម្បីធ្វើយ៉ាងណាឲ្យនិស្សិតចូលរៀនបានផុលផុសក្នុងវគ្គសិក្សាទាំងមូល ស្តីពីក្រមសីលធម៌គ្រូពេទ្យ និងមានការយល់ដឹងច្បាស់លាស់ពីក្រមសីលធម៌នេះ។ ការទទួលបានលក្ខណៈសម្បត្តិជាគ្រូពេទ្យល្អរបស់និស្សិត នឹងកាន់តែរឹងប៉ឹងឡើងទៀត បើសិនកម្មវិធីសិក្សាក្រៅផ្លូវការដែលនិស្សិតទទួលបានពីការអនុវត្តរបស់គ្រូពេទ្យ ក្នុងពេលចុះកម្មសិក្សានោះត្រូវបានយកមកដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាជាផ្លូវការ។

សរុបមក អ្នកអប់រំបណ្តុះបណ្តាលផ្នែកវេជ្ជសាស្រ្តគួរគិតគូរឡើងវិញពីវិធីសាស្រ្តបណ្តុះបណ្តាល និងទំនាក់ទំនងរវាងសិស្សនឹងគ្រូ។ មានវិធីមួយដែលគួរគិតគូរ គឺការប្តូរពីវិធីសាស្រ្តបង្រៀនដែលយកគ្រូធ្វើជាគោល មកជាវិធីសាស្រ្តយកសិស្សធ្វើជាគោលវិញតាមរយៈអន្តរកម្មជាលក្ខណៈបុគ្គលច្រើនជាងមុននៅក្នុងទំនាក់ទំនងរវាងសិស្សនឹងគ្រូ ដោយយកបទពិសោធន៍របស់និស្សិតធ្វើជាចំណុចចាប់ផ្តើម។ ជាការល្អបំផុត គ្រូពេទ្យនិងបុគ្គលិកសុខាភិបាលទាំងអស់នៅតាមមន្ទីរពេទ្យ គួរធ្វើខ្លួនជាគំរូល្អ ព្រោះខ្លួនមានភារកិច្ចនិងការទទួលខុសត្រូវពិសេស ក្នុងការដាក់បញ្ចូលគោលការណ៍នៃការអនុវត្តរបៀបរបបវិជ្ជាជីវៈពេទ្យល្អ ទៅក្នុងចិត្តគំនិតរបស់គ្រូពេទ្យក្មេងៗ និងនិស្សិតដែលខ្លួនមើលការខុសត្រូវ។

## ឯកសារយោង


ABIM (American Board of Internal Medicine). 1995. *Project Professionalism*. Philadelphia, PA: ABIM. https://medicinainternaucv.files.wordpress.com/2013/02/project-professionalism. pdf.

ABIM, ACP-ASIM and EFIM (American Board of Internal Medicine, American College of Physicians-American Society of Internal Medicine, European Federation of Internal Medicine). 2002. "Medical Professionalism in the New Millennium: A Physician Charter." *Annals of Internal Medicine* 136 (3): 243–246.

ACGME (Accreditation Council for Graduate Medical Education). 2007. *General Competencies*. www.ucdenver.edu/academics/colleges/medicalschool/departments/pediatrics/meded/fellowships/Documents/ACGME%20Outcome%20Project.pdf.

Ahadi,Tannaz, Elaheh Mianehsaz, Gholamreza Raissi, Seyed Alireza Moraveji and Vahid Sharifi. 2015. "Professionalism in Residents of Physical Medicine and Rehabilitation in Iran." *Journal of Medical Ethics and History of Medicine*. Teheran: Iran University of

Chhim Sarath. Forthcoming. *Strengthening Medical Professionalism at the University of Health Sciences, Cambodia*. Working Paper Series. Phnom Penh: CDRI.

Cruess Sylvia R. 2006. "Professionalism and Medicine's Social Contract with Society." Clinical Orthopaedics and Related Research (449): 170 – 176. DOI: 10.1097/01.blo.0000229275.66 570.97.

Doyle, Alison. 2018. "Career Path Definition with Examples." www.thebalancecareers.com/ career -path-definition-with-examples-2059765.

GMC and MSC (General Medical Council and Medical Schools Council). 2016. *Achieving Good Medical Practice Guidance for Medical Students*. www.gmc-uk.org/-/media/documents/ Achieving_good_medical_practice_0816.pdf_660 86678.pdf.

Marady Hai and Huaifu Xu. 2017. "Why People Prefer Seeking Care from One Country to Other Countries: A Case Study from Cambodia." *MOJ Public Health* 6 (4). DOI:10.15406/mojp h.2017.06.00178.

Mueller, Paul S. 2009. "Incorporating Professionalism into Medical Education: The Mayo Clinic Experience." *Keio Journal of Medicine* 58 (3): 133–143. doi.org/10.2302/kjm.58.133.

Mueller, Paul S. 2015. "Teaching and Assessing Professionalism in Medical Learners and Practicing Physicians" *Maimonides Medical Journal* 6 (2): e0011. doi: 10.5041/RMMJ.10195

NIS (National Institute of Statistics). 2015. *Cambodia Demographic and Health Survey 2014*. Phnom Penh: Ministry of Planning. https://dhsprogram.com/pubs/pdf/fr312/fr312.pdf.

Passi, Vimmi, Manjo Doug, Ed Peile, Jill Thistlethwaite and Neil Johnson. 2010. "Developing Medical Professionalism in Future Doctors: A Systematic Review." *International Journal of Medical Education* 1:19–29.

RGC (Royal Government of Cambodia). n.d. "Oath of Allegiance of Medical Professionals." www. mcc.org.kh/publications/16_fs_en.pdf.

RGC. 2003. *Sub-Decree on the Code of Medical Ethics*. www.mcc.org.kh/publications/17_fs_ en.pdf; www.mcc.org.kh/publications/17_ fs _kh.pdf.

Tallis, Raymond C. 2006. "Doctors in Society: Medical Professionalism in a Changing World." *Clinical Medicine* 6: 7–12.

WHO (World Health Organization). 2016. *Cambodia-WHO Country Cooperation Strategy 2016–2020*. Manila: WHO Regional Office for Western Pacific Region.

# តំបន់សេដ្ឋកិច្ចពិសេស ជាឧបករណ៍សម្រាប់ពន្លឿនកំណើនសេដ្ឋកិច្ច៖ ការសិក្សាលើឯកសារ

## ទស្សនទាន និងនិយមន័យ

តំបន់សេដ្ឋកិច្ចពិសេស (SEZs) កើតមានជាយូរមកហើយ ក្នុងទម្រង់ផ្សេងៗ ប៉ុន្តែចាប់ពីពាក់កណ្តាលទសវត្សរ៍១៩៩០ មក ទើបគេប្រើវាដោយចេតនា ធ្វើជាឧបករណ៍ផ្នែកគោលនយោបាយ។ សហរដ្ឋអាមេរិកបានបង្កើត SEZs ទី១ របស់ខ្លួន នៅក្រុងញ៉ូយ៉កក្នុងឆ្នាំ១៩៣៧ បន្ទាប់មកក្នុងឆ្នាំ១៩៤២ បាន កសាង SEZs នៅ កោះព័រតូរីកូ (Pakdeenurit, Suthikarnnarunai and Rattanawong 2014)។ ដោយឡែក តំបន់ឧស្សាហកម្មសេរីទំនើបទី១ ត្រូវបានផ្តួចផ្តើមនិងកសាង ឡើងនៅក្រុង Shannon ប្រទេសអៀរឡង់ ក្នុងឆ្នាំ១៩៥៩ (Farole and Akinci 2011)។ ចាប់ពីទសវត្សរ៍១៩៦០ មក SEZs បានក្លាយជាសមាសភាគដ៏សំខាន់នៃ យុទ្ធសាស្ត្រសេដ្ឋកិច្ចនិងឧស្សាហកម្មជាតិ ក្នុងទូទាំងពិភពលោក ជាពិសេសនៅ អាស៊ីខាងកើត និង អាមេរិកឡាទីន។ ឧទាហរណ៍ ប្រទេសកូឡុំប៊ី បានបង្កើតតំបន់ទី១ របស់ខ្លួនឈ្មោះថា Barranquilla ក្នុងឆ្នាំ ១៩៦៤។ មួយឆ្នាំក្រោយមក សាធារណរដ្ឋដូមីនីក បានដើរតាម ប្រទេសកូឡុំប៊ី ដោយបង្កើតតំបន់ La Romana ក្នុងឆ្នាំ១៩៦៥ (Farole 2011)។ នៅអាស៊ី ប្រទេសឥណ្ឌាបានបង្កើត SEZs ទី១ របស់ខ្លួនក្នុងឆ្នាំ១៩៦៥ តៃវ៉ាន់បានបង្កើតវាក្នុងឆ្នាំ១៩៦៦ កូរ៉េខាងត្បូងបានបង្កើតក្នុងឆ្នាំ១៩៧០ ហើយ ចិនបានបង្កើត ក្នុងឆ្នាំ១៩៨០ (Farole 2011)។ ខណៈដែល សហរដ្ឋអាមេរិក ជាអ្នកនាំមុខគេលើ SEZs ទំនើប ឥណ្ឌាមាន SEZs ច្រើនជាងគេ ហើយ SEZs នៅចិន ត្រូវបានចាត់ទុកថាមានជោគជ័យខ្លាំង បំផុត ជាពិសេសនៅក្រុង Shenzhen។ ជោគជ័យនៃ SEZs នៅចិន បានទាក់ទាញចំណាប់អារម្មណ៍ច្រើនណាស់ពីសំណាក់ អ្នកសិក្សាស្រាវជ្រាវ អ្នកកសាងគោលនយោបាយ និងអ្នកអភិវឌ្ឍឧស្សាហកម្ម ទូទាំងពិភពលោក។ មកទល់សព្វថ្ងៃ SEZs ផ្សេងៗ ដូចជា តំបន់ពាណិជ្ជកម្មសេរី តំបន់កែច្នៃសម្រាប់ការនាំចេញ ឧទ្យានឧស្សាហកម្ម កំពង់ផែសេរី និង តំបន់សហគ្រាស ជាដើម បណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានប្រើប្រាស់វា ដើម្បីពន្លឿន ការនាំចេញ ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស(FDI) និងធ្វើ ឧស្សាហូបនីយកម្មសេដ្ឋកិច្ច។

ពាក្យ SEZs មួយអាចនាំមកនូវ រូបភាពខុសៗគ្នាជាខ្លាំង ដូចជា៖ បណ្តុំឧស្សាហកម្មបិទជិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងពោរពេញទៅដោយបណ្តាក្រុមហ៊ុនពហុជាតិ ដែលអាចនឹង ប្តូរទីតាំងផលិតយ៉ាងងាយស្រួល, "អព្ភូតហេតុសេដ្ឋកិច្ចនៃក្រុង Shenzhen" ដែលដើមឡើយជាភូមិនេសាទដាច់ស្រយាលហើយ បានរីកលូតលាស់ជា ទីក្រុងមានសន្ទុះខ្លាំងបំផុតក្នុងពិភពលោក និងជារដ្ឋធានីនៃនវានុវត្តន៍នៅចិន, និងមជ្ឈមណ្ឌលឡូជីស្ទិក និង ពាណិជ្ជកម្មលំដាប់ពិភពលោកនៅទីក្រុងឌូបៃ និងប្រទេសសិង្ហបុរី ជាដើម (Farole and Akinci 2011)។ ជារួម SEZs ភាគច្រើន តែងមានលក្ខណៈសំគាល់ដូចតទៅ៖ ១) តំបន់មានព្រំដែន កំណត់ច្បាស់ និងមានសន្តិសុខ ២) តំបន់គ្រប់គ្រងដោយអង្គភាព គ្រប់គ្រង ឬរដ្ឋបាលតែមួយ ៣) តំបន់មានផ្តល់ឧត្តមភាពទៅ តាមទីតាំងរបស់ខ្លួន ៤) តំបន់ស្ថិតក្រោមរបបពន្ធគយពិសេស និង នីតិវិធីគេបានរៀបចំឲ្យសាមញ្ញឡើង (Shakya 2009)។ ក្នុងនេះ លក្ខណៈទី៤ ជាលក្ខណៈសំគាល់សំខាន់ជាងគេនៃ SEZ (Farole 2011) ពីព្រោះលក្ខណៈសំគាល់ឯទៀតវាខុសៗគ្នាខ្លាំងណាស់។ ផ្ទុយទៅវិញ គំរូ SEZ នៅចិន គេបានកំណត់ថាជា សកម្មភាព និង សេវាកម្មសេដ្ឋកិច្ចដែលជាប់ទាក់ទងគ្នាយ៉ាងស្មុគស្មាញ គឺមិនមែន ជា អង្គភាពដែលមានមុខងារតែមួយនោះទេ។ ដូច្នេះហើយ SEZs នៅចិន តែងមានទំហំធំជាង និងបម្រើមុខងារច្រើនមុខជាង SEZs នៅប្រទេសផ្សេងទៀត (Wong 1987; Zeng 2010)។

Shah (2008, 4) បានកំណត់ SEZs ថាជា "តំបន់ភូមិសាស្ត្រ មានបរិវេណជាក់លាក់នៅក្នុងប្រទេសនានា ពោលគឺ ផ្ទៃដីមាន ព្រំប្រទល់កំណត់ច្បាស់ ដែលគេប្រើប្រាស់ដើម្បីលើកទឹកចិត្តដល់ ឧស្សាហកម្ម កម្មន្តសាលកម្ម និងសេវាកម្មផ្សេងៗសម្រាប់បម្រើ ការនាំចេញ ហើយតំបន់ទាំងនោះ ច្រើនតែអាចសំគាល់បានដោយ សារមានគោលនយោបាយសេដ្ឋកិច្ច និងច្បាប់ពន្ធដារ ធូរ ទូលាយ"។ Farole (2011, 23) បានកំណត់និយមន័យ SEZs ស្រដៀងគ្នាដែរ ប៉ុន្តែសព្វគ្រប់ជាង ដូចខាងក្រោមនេះ៖

> តំបន់ភូមិសាស្ត្រ មានព្រំប្រទល់កំណត់ច្បាស់ ស្ថិតក្នុងរង្វង់ព្រំដែនជាតិ របស់ប្រទេសមួយជាក់លាក់ ហើយតំបន់នោះមានវិធានច្បាប់ផ្នែកអាជីវកម្ម ខុសប្លែកពីវិធានច្បាប់ ដែលមានអនុវត្តជាទូទៅនៅក្នុង ទឹកដីប្រទេសនោះ។ វិធានច្បាប់ខុសប្លែកគេទាំងនេះ ច្រើនពាក់ព័ន្ធទៅនឹង លក្ខខណ្ឌក្នុងការធ្វើវិនិយោគ ពាណិជ្ជកម្មអន្តរជាតិនិងបែបបទគយ ការយកពន្ធ និងក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ ពោលគឺ គេផ្តល់ ឲ្យតំបន់នោះនូវ បរិយាកាសអាជីវកម្មមួយដែលមាន គោលនយោបាយធូរទូលាយជាង និងមានការគ្រប់គ្រង រដ្ឋបាលប្រកបដោយប្រសិទ្ធភាពជាង បើធៀបនឹងទឹកដី ជាទូទៅរបស់ប្រទេសជាតិនោះ។

---

អត្ថបទនេះរៀបរៀងឡើងដោយ បណ្ឌិត វ៉ែន សីហា អ្នកស្រាវជ្រាវនៅផ្នែកសេដ្ឋកិច្ចនៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា Ven Seyhah. 2018. “Special Economic Zones as a Tool for Accelerating Economic Growth: A Literature Review.” *Cambodia Development Review* 22 (1): 7-11.

## ម៉ូដែលនៃតំបន់សេដ្ឋកិច្ចពិសេស

ម៉ូដែលនៃ SEZs មានច្រើនបែបច្រើនសណ្ឋាន ទៅតាមគោលដៅផ្នែកគោលនយោបាយ គោលគំនិតស្តីពី SEZs និងយុទ្ធសាស្ត្របែងចែកប្រភេទ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ប្រទេសនីមួយៗ ដូច្នេះហើយ ការធ្វើចំណាត់ថ្នាក់ SEZs ក៏ជួបការលំបាក។ ដោយផ្អែកលើរបៀបធ្វើចំណាត់ថ្នាក់ស្មើឡើងដោយ Akinci and Crittle (2008) និង Farole (2011), Farole and Akinci (2011) បានបែងចែក SEZs ជា ៥ម៉ូដែល ទៅតាម គោលដៅអភិវឌ្ឍន៍ ទំហំ ទីតាំង សកម្មភាព និង ទីផ្សារ គឺមាន តំបន់ជំនួញ/ពាណិជ្ជកម្មសេរី(FTZ) តំបន់កែច្នៃសម្រាប់ការនាំចេញបែបប្រពៃណី(EPZ) សហគ្រាសសេរី(FE)/EPZ មានតែមួយអង្គភាព EPZ បែបកូនកាត់ និងផែសេរី ដូចមានបញ្ជាក់សង្ខេបក្នុង តារាង១ ។

## តំបន់សេដ្ឋកិច្ចពិសេស ក្នុងលក្ខណៈជាឧបករណ៍ផ្នែកគោលនយោបាយ

ហេតុផលក្នុងការបង្កើត SEZs គឺការរំពឹងថា វាជួយពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច ដោយសម្រេចគោលដៅផ្នែកគោលនយោបាយបានលឿនជាងករណីគ្មានវា។ កន្លងមកគេតែងប្រើវាដើម្បីទាក់ទាញ វិនិយោគផ្ទាល់ពីបរទេស(FDI) កាត់បន្ថយភាពគ្មានការងារធ្វើ ជួយទ្រទ្រង់កំណែទម្រង់សេដ្ឋកិច្ច និង សាកល្បងយន្តការ និងវិធីសាស្ត្រផ្នែកគោលនយោបាយថ្មីៗ (Akinci and Crittle 2008; Farole 2011; Farole and Akinci 2011)។

***ការទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស៖*** កម្មវត្ថុចម្បងនៃ SEZs គឺទាក់ទាញវិនិយោគផ្ទាល់ពីបរទេស។ ចំណុចនេះសំខាន់ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះ SEZs ស្ទើរតែទាំងអស់ត្រូវបានបង្កើតឡើង ដើម្បីទាក់ទាញវិនិយោគក្នុងវិស័យប្រើពលកម្មច្រើន និងផ្តោតលើការនាំចេញដូចជា ផ្នែកកាត់ដេរសម្លៀកបំពាក់និងផលិតស្បែកជើង និងការផ្គុំតម្លើងគ្រឿងបង្គុំអេឡិចត្រូនិក និងយានយន្ត ជាដើម។

***ការកាត់បន្ថយភាពគ្មានការងារធ្វើ៖*** ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន មានពលករមានជំនាញទាប និងប្រៀវត្សរ៍ទាប ច្រើនណាស់ ហើយ SEZs អាចស្រូបយកកម្លាំងពលកម្មដ៏សម្បូរនេះ ដែលបើមិនដូច្នោះទេ នឹងត្រូវបម្រើការមិនអស់លទ្ធភាព ឬក៏គ្មានការងារធ្វើតែម្តង។ SEZs នៅប្រទេសទុយនីស៊ី និងសាធារណរដ្ឋដូមីនីក គេតែងលើកជារឿយៗធ្វើជា ឧទាហរណ៍នៃ គំរូ SEZs ដែលបានជួយបង្កើតការងារជាបន្តបន្ទាប់រហូតដល់សព្វថ្ងៃ។

តារាង១៖ លក្ខណៈសំគាល់នៃ SEZ បែបផ្សេងៗ

| | FTZ | EPZ | FE | EPZ កូនកាត់ | ផែសេរី |
|---|---|---|---|---|---|
| គោលដៅ | ទ្រទ្រង់ពាណិជ្ជកម្ម | ពន្លឿនការនាំចេញផលិតផលកម្មន្តសាល | ពន្លឿនការនាំចេញផលិតផលកម្មន្តសាល | ពន្លឿនការនាំចេញផលិតផល | ជម្រុញការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ដោយប្រមូលផ្តុំធនធានសេដ្ឋកិច្ច |
| ទំហំ | <50 ហិកតា | <100 ហិកតា | តំបន់គ្មានកំណត់បរិវេណ | - ផ្នែកខ្លះកំណត់ថាជា EPZ បែបប្រពៃណី<br>- ផ្នែកខ្លះបើកចំហសម្រាប់ក្រុមហ៊ុនគ្រប់ប្រភេទ | ធំទូលាយ (ប្រភេទធំបំផុត) មានតំបន់លំនៅដ្ឋាន និងមជ្ឈមណ្ឌលដឹកជញ្ជូន (ឧ. ផែ, អាកាសយានដ្ឋាន) |
| ទីតាំង | ផែសមុទ្រ និងអាកាសយានដ្ឋាន | គ្មានទីតាំងរួមគ្នា | កន្លែងណាក៏បាន ឬក្នុងតំបន់កំណត់ | មិនពាក់ព័ន្ធ | មិនពាក់ព័ន្ធ |
| សកម្មភាព | - ដឹកឆ្លងកាត់<br>- ពាណិជ្ជកម្ម | - ការផលិតនិងកែច្នៃជាសំខាន់សម្រាប់នាំចេញ<br>- ខ្លះមានការកែសម្រួលដើម្បីអាចធ្វើសកម្មភាពច្រើនទៀត | សកម្មភាពផលិតនិងកែច្នៃបម្រើការនាំចេញ | - ការផលិតនិងកែច្នៃជាសំខាន់សម្រាប់នាំចេញ<br>- ខ្លះមានការកែសម្រួលដើម្បីអាចធ្វើសកម្មភាពច្រើនទៀត | គ្រប់សកម្មភាពសេដ្ឋកិច្ច |
| ទីផ្សារ | ក្នុងស្រុក, នាំចេញទៅវិញ | នាំចេញ | នាំចេញ | នាំចេញ, ក្នុងស្រុក | ក្នុងតំបន់ ក្នុងស្រុក, នាំចេញ |
| គំរូមួយចំនួន | Colón FTZ នៅប៉ាណាម៉ា (បើកឆ្នាំ១៩៤៨) | Masan FTZ នៅកូរ៉េខាងត្បូង (បើកឆ្នាំ១៩៧០) | ម៉ូរីស និង ម៉ិកស៊ិក | Lat Krabang នៅថៃ | Aqaba នៅហ្ស៊កដានី SEZs នៅចិន |

Sources: Akinci and Crittle 2008; Farole 2011; Farole and Akinci 2011

តារាង២៖ លក្ខណៈសំគាល់ និងផលប៉ះពាល់នៃ SEZs ទៅតាមដំណាក់កាលអភិវឌ្ឍន៍នៃប្រទេសម្ចាស់ផ្ទះ

| ដំណាក់កាលអភិវឌ្ឍន៍ | | ការចូលរួមចំណែករំពឹងទុក | |
|---|---|---|---|
| SEZ ជាកតាលីករ | ប្រទេសម្ចាស់ផ្ទះ | បិតិវន្ត | ថាមវន្ត |
| តំបន់ដោយឡែក | សេដ្ឋកិច្ចផ្អែកលើកសិកម្ម<br>ប្រទេសមានចំណូលទាប<br>ពលកម្មតម្លៃទាប មិនជំនាញ | FDI<br>ការងារ<br>កំណើននាំចេញ | |
| ការតភ្ជាប់ទៅនឹងសេដ្ឋកិច្ចក្នុងស្រុក | ប្រទេសមានចំណូលមធ្យម<br>ខ្សែសង្វាក់តម្លៃ/សហគ្រាសក្នុងស្រុករឹងមាំ<br>តម្លៃពលកម្មកើនឡើង<br>ពលកម្មជំនាញ ឬពាក់កណ្ដាលជំនាញ | | ការបង្កើនកម្រិតជំនាញ<br>ការផ្ទេរបច្ចេកវិទ្យា<br>ពិពិធកម្មការនាំចេញ<br>បង្កើនប្រសិទ្ធភាពធ្វើជំនួញនៃសហគ្រាសក្នុងស្រុក<br>កញ្ចុំឧស្សាហកម្ម<br>ការចូលរួមក្នុងខ្សែសង្វាក់តម្លៃសកល |
| សម្រួលការបង្កើតកញ្ចុំឧស្សាហកម្ម, នវានុវត្តន៍ និង SEZs ឯកទេស | សេដ្ឋកិច្ចឧស្សាហកម្ម | | ការបង្កើតកញ្ចុំឧស្សាហកម្ម<br>នវានុវត្តន៍ |

Source: adopted from Warr and Menon 2015

***ការជួយទ្រទ្រង់ យុទ្ធសាស្ត្រកែទម្រង់សេដ្ឋកិច្ចធំទូលាយ៖*** SEZs ជាយន្តការងាយស្រួលមួយដែលជួយឲ្យប្រទេសមួយចំនួនអាចធ្វើពិពិធកម្មទំនិញនាំចេញ និងកាត់បន្ថយរបាំងរារាំងការនាំចេញ ដោយអាចរក្សាទុកដដែលនូវវិធានការគាំពារផ្សេងៗទៀតនៅក្នុងប្រទេស។ SEZs នៅចិន កូរ៉េខាងត្បូង ម៉ូរីស និង តៃវ៉ាន់ សុទ្ធតែដើរតាមលំនាំនេះ។

***ការសាកល្បងយន្តការ និងវិធីសាស្ត្រថ្មីៗ ផ្នែកគោលនយោបាយ៖*** ចិនបានប្រើប្រាស់ SEZs ជាមន្ទីរពិសោធន៍សម្រាប់សាកល្បងគោលនយោបាយបើកចំហ និងកំណែទម្រង់សេដ្ឋកិច្ចរបស់ខ្លួនក្នុងទសវត្សរ៍១៩៨០ នៅពេលប្រទេសចិនកំពុងមានសេដ្ឋកិច្ចបិទទ្វារនៅឡើយ។ វិធីសាស្ត្រពិសោធន៍មើលនេះ គួបផ្សំនឹងផ្ទត់គំនិតផ្ដោតលើកំណែទម្រង់ផង ក៏ទទួលបានជោគជ័យខ្លាំងមែន។

## ការរីកចម្រើន និងចូលរួមចំណែកនៃតំបន់សេដ្ឋកិច្ចពិសេស

SEZs បានចូលរួមចំណែកដល់ការអភិវឌ្ឍជាតិច្រើនណាស់ និងលើសពីគោលដៅបឋម ផ្នែកគោលនយោបាយទៅទៀត។ ការចូលរួមចំណែកទាំងនេះ អាចបែងចែកជាប្រភេទ បិតិវន្ត (static) និង ថាមវន្ត (dynamic)។ ការចូលរួមចំណែកបិតិវន្ត រួមមាន វិនិយោគផ្ទាល់ពីបរទេស(FDI) ការមានការងារធ្វើ និងកំណើនការនាំចេញ។ ការចូលរួមចំណែកថាមវន្ត រួមមាន ការបង្កើនកម្រិតជំនាញ ការផ្ទេរបច្ចេកវិទ្យា ពិពិធកម្មការនាំចេញ ការកែលំអប្រសិទ្ធភាពធ្វើជំនួញនៃសហគ្រាសក្នុងស្រុក ការបង្កើតកញ្ចុំឧស្សាហកម្ម និងការចូលរួមក្នុងខ្សែសង្វាក់តម្លៃសកល។ ប៉ុន្តែមានភស្តុតាងបង្ហាញថា ការចូលរួមចំណែករបស់ SEZs ប្រែប្រួលខុសគ្នាពី ប្រទេសមួយទៅប្រទេសមួយ ទៅតាមដំណាក់កាលអភិវឌ្ឍន៍នៃប្រទេសម្ចាស់ផ្ទះ។ Warr and Menon (2015) បានបែងចែក លក្ខណៈសំគាល់ និងផលប៉ះពាល់នៃ SEZs ទៅតាមដំណាក់កាលអភិវឌ្ឍន៍នៃប្រទេសម្ចាស់ផ្ទះ ដូចមានក្នុងតារាង២។

## លទ្ធផល និងបញ្ហាប្រឈមនៃតំបន់សេដ្ឋកិច្ចពិសេស

SEZs ជាច្រើនទទួលជោគជ័យ ប៉ុន្តែមានច្រើនទៀតមិនបានសម្រេចតាមគោលដៅ ផ្នែកគោលនយោបាយរបស់ខ្លួនទេ ដូចជា នៅឥណ្ឌា SEZs ខ្លះមានជោគជ័យ និងខ្លះទៀតទទួលបរាជ័យ។ ការស្រាវជ្រាវជាក់ស្តែងបង្ហាញថា SEZs ជាច្រើនមានជោគជ័យក្នុងការបង្កើតការងារ និងបង្កើនការនាំចេញ ហើយបង្ហាញលទ្ធផលវិជ្ជមានខ្លះដែរ តាមការវិភាគចំណាយធៀបនឹងផលចំណេញ (Chen 1993; Jayanthakumaran 2004; Monge-González, Rosales-Tijerino and Arce-Alpízar 2005; Warr 1989 cited in Farole and Akinci 2011)។

បទពិសោធន៍សកលលើ SEZs បង្ហាញថា SEZs ដើរតួនាទីសំខាន់ក្នុង កំណើនសេដ្ឋកិច្ច ឧស្សាហូបនីយកម្ម និង ពិពិធភាពសេដ្ឋកិច្ច។ ខ្លាអាស៊ីទាំងបួន (ហុងកុង សិង្ហបុរី កូរ៉េខាងត្បូង និងតៃវ៉ាន់) អាចរក្សាបាននូវអត្រាកំណើនយ៉ាងខ្ពស់ចាប់តាំងពីដើមទសវត្សរ៍១៩៦០ មក ហើយបន្ទាប់មកគឺ ប្រទេសចិនដែលបានស្ទុះឡើង តាំងពីពាក់កណ្ដាលទសវត្សរ៍១៩៨០។ ក្នុងប្រទេសទាំងនេះ SEZs បានដើរតួនាទីសំខាន់ក្នុងការបង្កើនគុណភាព និងធ្វើទំនើបកម្មឧស្សាហកម្ម និងក្នុងការរៀបចំឡើងវិញយ៉ាងលឿននូវរចនាសម្ព័ន្ធសេដ្ឋកិច្ច។ នៅម៉ូរីសបូព៌ា និងអាហ្វ្រិកខាងជើង SEZs ជាកត្តាស្នូលជួយជម្រុញកំណើន និងពិពិធកម្មការនាំចេញ។ នៅអាហ្វ្រិក SEZs នៃបណ្ដាប្រទេសខាងត្បូងវាលខ្សាច់សាហារ៉ា បានចូលរួមចំណែកយ៉ាងច្រើន ដល់ពិពិធកម្មសេដ្ឋកិច្ច និងឧស្សាហូបនីយកម្មប្រកបដោយជោគជ័យ។ នៅអាមេរិកឡាទីន

ប្រទេស អែលសាល់វ៉ាឌ័រ ហុងឌូរ៉ាស និង សាធារណៈរដ្ឋដូមីនីក បានប្រើ SEZs ដើម្បីរំកិលខ្លួនចេញពីការពឹងផ្អែកលើទំនិញកសិកម្ម ទៅធ្វើកម្មន្តសាលកម្មខ្នាតធំ និងទាញយកចំណេញពីការទទួលបានលក្ខខណ្ឌអនុគ្រោះ ដើម្បីចូលទៅក្នុងទីផ្សារសហរដ្ឋអាមេរិក (Farole and Akinci 2011)។

ទោះយ៉ាងនេះក្តី SEZs ក៏មានចំណុចមិនល្អដែរ។ មានភស្តុតាងបង្ហាញថា ការធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ SEZ ជារឿយៗ វាអស់ច្រើនជាង ផលចំណេញទទួលបាន ដោយសហគ្រាសនានាគេងយកចំណេញពីការលើកទឹកចិត្តនិងបុព្វសិទ្ធិផ្សេងៗដែលមាននៅក្នុង SEZs ទោះបីជាគ្រោងការជាច្រើនមិនបានសម្រេចតាមគោលដៅក្តី (Farole and Akinci 2011)។ SEZs ជាច្រើនសម្រេចបានតែអត្ថប្រយោជន៍បិតិវន្ត ហើយមិនសម្រេចបាននូវអត្ថប្រយោជន៍ថាមវន្តទេ (Kaplinsky 1993)។ អ្នកសិក្សាស្រាវជ្រាវជាច្រើនមើលឃើញ SEZs ថាជា ឧបករណ៍ផ្នែកគោលនយោបាយល្អបំផុតទី២ ឬទី៣ សម្រាប់កែលំអសមត្ថភាពប្រកួតប្រជែង ដោយរំកញែកថា SEZs អាចរីកលូតលាស់តែក្នុងស្ថានភាពជាក់លាក់ខ្លះ និងក្នុងអំឡុងពេលមានកំណត់មួយ (Hamada 1974; Madani 1999; World Bank 1992)។ SEZs អាចទទួលជោគជ័យ លុះត្រាតែមានហេដ្ឋារចនាសម្ព័ន្ធជួយទ្រទ្រង់គ្រប់គ្រាន់ ហើយឥទ្ធិពលនៃការរីកលូតលាស់របស់វា គឺអាស្រ័យលើដំណាក់កាលអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសម្ចាស់ផ្ទះ។

## កត្តាផ្តល់ជោគជ័យសំខាន់ៗ សម្រាប់តំបន់សេដ្ឋកិច្ចពិសេស

មានកត្តាជាច្រើនចូលរួមចំណែកក្នុងជោគជ័យនៃ SEZs ដូចជា ការជម្រះពន្ធគយលឿន បទបញ្ញត្តិធូរស្រាល ការតភ្ជាប់ជាសកលកម្រិតខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធមានកម្រិតអភិវឌ្ឍន៍ខ្ពស់ ភាពសម្បូរកម្លាំងពលកម្មជំនាញនិងពាក់កណ្តាលជំនាញ គ្រឿងលើកទឹកចិត្តផ្តល់ផលចំណេញច្រើន បែបបទការិយាធិបតេយ្យមានតិចបំផុត របបម៉ាក្រូសេដ្ឋកិច្ចបើកចំហ និងគោលនយោបាយផ្នែកពន្ធដារជួយរក្សាស្ថិរភាពហិរញ្ញវត្ថុ។ បរិយាកាសវិនិយោគក្នុងស្រុកក៏ជះឥទ្ធិពលលើលទ្ធផលSEZsដែរក្នុងនេះការរីកលូតលាស់ជំនួញក្នុងស្រុកយ៉ាងលឿន តែងជួយទាក់ទាញជំនួញ និងវិនិយោគផ្ទាល់ពីបរទេស បានកាន់តែច្រើនទៀត (Aggarwal 2012)។

## បទពិសោធន៍រៀនសូត្របានពីតំបន់សេដ្ឋកិច្ចពិសេសនៅចិន

ប្រទេសចិនបានបង្កើត SEZs ដំបូងៗរបស់ខ្លួនក្នុងទសវត្សរ៍ ១៩៨០ ដើម្បីដកពិសោធន៍ធ្វើកំណែទម្រង់គាំទ្រទីផ្សារសេរី ក្នុងពេលកំពុងអនុវត្តរបបសេដ្ឋកិច្ចតាមផែនការប្រមូលផ្តុំនៅឡើយ។ គោលដៅសំខាន់គឺដើម្បី ធ្វើតេស្តគោលនយោបាយ និងស្ថាប័នថ្មីៗសម្រាប់បម្រើសេដ្ឋកិច្ចទីផ្សារ។ SEZ របស់ក្រុង Shenzhen ទទួលជោគជ័យជាខ្លាំង ហើយ SEZs ក៏បានផុសឡើងទូទាំងប្រទេស។ មានកត្តាជាច្រើនចូលរួមចំណែកក្នុងជោគជ័យនៃ SEZs នៅចិន ដូច Zeng (2010) បានគូសបញ្ជាក់ស្រាប់៖

- ការប្តេជ្ញាចិត្តខ្ពស់ ភាពងាយអនុវត្ត ភាពអាចបត់បែន និងឯករាជ្យភាពនៃអ្នកដឹកនាំកំពូល ផ្តល់នូវស្ថិរភាពកម្រិតខ្ពស់ផ្នែកគោលនយោបាយ និងទំនុកចិត្តដល់វិនិយោគិន នៅតាមកន្លែងត្រូវបង្កើត SEZs។
- វិធីសាស្ត្រមួយជំហានម្តងៗ និងងាយអនុវត្ត គឺមិនមែនកំណែទម្រង់យ៉ាងលឿននោះទេ ដើម្បីជៀសវាងផលវិបាកផ្សេងៗ ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ដូច Deng Xiaoping បានលើកឡើងក្នុងទស្សនវិជ្ជាកំណែទម្រង់របស់គាត់ថាជា "ការឆ្លងស្ទឹងដោយស្ទាបថ្ម"។
- SEZs នានាតែងមានជាស្រេចនូវ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដ៏ចាំបាច់ៗ ដូចជា ផ្លូវថ្នល់ ទឹកស្អាត អគ្គិសនី ឧស្ម័ន និងទូរស័ព្ទ ជាដើម ដែលផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការបង្កើតទីផ្សារតាមជំនាញឯកទេស វេទិកាសម្រាប់នវានុវត្តន៍ផ្នែកបច្ចេកវិទ្យា និងមជ្ឈមណ្ឌលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D)។ SEZs ក៏មានសិទ្ធិអំណាចបង្កើតបទបញ្ញត្តិរបស់ខ្លួនផ្ទាល់ ដើម្បីចូលរួមចំណែកញាំងឲ្យមានការគ្រប់គ្រងអាជីវកម្មប្រកបដោយប្រសិទ្ធភាព។ រដ្ឋាភិបាលបានប្រឹងប្រែងជាខ្លាំង ក្នុងការបង្កើនសមត្ថភាពផ្នែកបច្ចេកវិជ្ជា និងនវានុវត្តន៍ តាមការបង្កើនវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធសម្រាប់ R&D និងការផ្តល់គ្រឿងលើកទឹកចិត្តពិសេសៗ ដើម្បីទាក់ទាញក្រុមហ៊ុនប្រើបច្ចេកវិជ្ជាទំនើបៗ និងអ្នកវិទ្យាសាស្ត្រ និងវិស្វករមានសមត្ថភាពខ្ពស់ៗ។ ភាពជាដៃគូរវាងវិស័យសាធារណៈនឹងឯកជន រួមទាំងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនិងមជ្ឈមណ្ឌលសម្រាប់ R&D ផង ក៏ដើរតួនាទីសំខាន់ដែរ។
- ប្រជាជនចិនដែលចេញទៅរស់នៅខាងក្រៅប្រទេស បានចូលរួមចំណែកគួរឲ្យកត់សំគាល់ដល់ជោគជ័យនៃ SEZs ជាពិសេសតាមរយៈ ការផ្ទេរចំណេះដឹងក្នុងរូបភាពជាជំនាញ និងបច្ចេកវិទ្យា វិនិយោគជាមូលធន និងសហគ្រិនភាព នៅក្នុងទសវត្សរ៍១៩៨០។ នៅពេលនោះ ក្រុងហុងកុង ម៉ាកាវ និងតៃវ៉ាន់ កំពុងត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការផ្លាស់ប្តូរទីតាំងមូលដ្ឋានផលិតកម្មកម្មន្តសាល ប្រើពលកម្មច្រើនរបស់ខ្លួន។ ដោយសារ មានភាសានិងវប្បធម៌ស្រដៀងគ្នា និងមានទីតាំងនៅជិតគ្នា វិនិយោគផ្ទាល់ពីបរទេសក៏បានហូរចេញពីតំបន់ទាំងនេះទៅកាន់ SEZs នៅចិន។
- SEZs នៅចិន មានផែនការអភិវឌ្ឍន៍និងគោលដៅច្បាស់លាស់ ដើម្បីចូលរួមចំណែក ជំរុញកំណើន ផសស បង្កើតការងារ ពន្លឿនការនាំចេញ ទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស ព្រមទាំង ទទួលបានចំណូលពន្ធផ្សេងៗ ។ SEZs ទាំងនេះមានការប្រកួតប្រជែងគ្នាជាខ្លាំង ដែលលើកទឹកចិត្តឲ្យសហគ្រាសនានាកាន់តែបង្កើនប្រសិទ្ធភាព និងផលិតភាព។ រដ្ឋាភិបាលធ្វើការត្រួតពិនិត្យ និងតាមដានយ៉ាងជិតដល់នូវ ផែនការអភិវឌ្ឍន៍ គោលដៅ និងការប្រកួតប្រជែង។

## ឯកសារយោង


Aggarwal, Aradhna. 2012. “SEZ-Led Growth in Taiwan, Korea, and India: Implementing a Successful Strategy.” *Asian Survey* 52 (5): 872–99. doi:10.1525/as.2012.52.5.872.

Akinci, Gokhan, and James Crittle. 2008. “Special Economic Zone : Performance, Lessons Learned, and Implication for Zone Development.” 45869. World Bank. http://documents .worldbank.org/curated/en/343901468330977533/Special-economic-zone-performance-lessons-learned-and-implication-for-zone-development.

Chen, Jinghan. 1993. “Social Cost-Benefit Analysis of China’s Shenzhen Special Economic Zone.” *Development Policy Review* 11 (3): 261–72. doi:10.1111/j.1467-7679.1993.tb00 041.x.

Farole, Thomas. 2011. *Special Economic Zones in Africa : Comparing Performance and Learning from Global Experience*. World Bank. https://openknowledge.worldbank.org/ handle/10986/2268.

Farole, Thomas, and Gokhan Akinci. 2011. *Special Economic Zones : Progress, Emerging Challenges, and Future Directions*. World Bank. https://openknowledge.worldbank.org/ handle/10986/2341.

Hamada, Koichi. 1974. “An Economic Analysis of the Duty-Free Zone.” *Journal of International Economics* 4 (3): 225–41. doi:10.1016/0022-1996(74)90044-0.

Jayanthakumaran, Kankesu. 2004. “Benefit-Cost Appraisals of Export Processing Zones: A Survey of the Literature.” https://papers.ssrn.com/abstract=376569.

Kaplinsky, Raphael. 1993. “Export Processing Zones in the Dominican Republic: Transforming Manufactures into Commodities.” *World Development* 21 (11): 1851–65. doi:10.1016/0305-750X(93)90087-P.

Madani, Dorsati. 1999. *A Review of the Role and Impact of Export Processing Zones*. Policy Research Working Papers. World Bank. doi:10.1596/1813-9450-2238.

Monge-González, Ricardo, Julio Rosales-Tijerino and Gilberto Arce-Alpízar. 2005. “Cost-Benefit Analysis of the Free Trade Zone System: The Impact of Foreign Direct Investment in Costa Rica.” OAS Trade, Growth and Competitiveness Studies. Washington, DC: Organization of American States Office of Trade, Growth and Competitiveness. http://citeweb.info/20050632506.

Pakdeenurit, P., N. Suthikarnnarunai and W. Rattanawong. 2014. “Special Economic Zone: Facts, Roles, and Opportunities of Investment.” Proceedings of the International Multi Conference of Engineers and Computer Scientists 2014 Vol II, 1047–51, Hong Kong, 12–14 Mar 2014.

Shah, Semil. 2008. *Special Economic Zones in South Asia: A Comparative Analysis of Bangladesh, Sri Lanka, and India*. Cambridge, MA: John F. Kennedy School of Government.

Shakya, Mallika. 2009. “Clusters for Competitiveness: A Practical Guide and Policy Implications for Developing Cluster Initiatives.” SSRN Scholarly Paper ID 1392479. Rochester, NY: Social Science Research Network. https://papers.ssrn.com/abstract= 1392479.

Warr, Peter G. 1989. “Export Processing Zones: The Economics of Enclave Manufacturing.” *World Bank Research Observer* 4 (1): 65–88.

Warr, Peter, and Jayant Menon. 2015. “Cambodia’s Special Economic Zones.” Arndt-Corden Department of Economics. https://acde.crawford.anu.edu.au/publication/working-papers-trade-and-development/7804/cambodias-special-economic-zones.

Wong, Kwan-Yiu. 1987. “China’s Special Economic Zone Experiment: An Appraisal.” Geografiska Annaler. Series B, Human Geography 69 (1): 27–40. doi:10.2307/490409.

World Bank. 1992. “Export Processing Zones.” 10500. World Bank. http://documents.worldbank. org/curated/en/400411468766543358/Export-processing-zones.

Zeng, Douglas Zhihua. 2010. *Building Engines for Growth and Competitiveness in China: Experience with Special Economic Zones and Industrial Clusters*. World Bank. https://openknowledge.worldbank.org/handle/10986/2501.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពិពណ៌នាពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍នៅត្រីមាសទី៤ ឆ្នាំ២០១៧។ ក្នុងត្រីមាសនេះ ផសស ពិត នៅឥណ្ឌូនេស៊ី មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៥,២% ឬខ្ពស់ជាងត្រីមាសទី៣ ០,១ ឯកតាភាគរយ និងជំរុញឡើងដោយសារមានវិនិយោគខ្លាំងក្នុងវិស័យឯកជន និងសាធារណៈ។ កំណើននៅម៉ាឡេស៊ី មានដល់ ៥,៩% ធៀបនឹង ៦,២% នៅត្រីមាសទី៣ និងជំរុញឡើងដោយសារតម្រូវការឯកជន និងវិស័យផ្សេងៗនៅក្រៅប្រទេស។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅសិង្ហបុរី ថយចុះមកត្រឹម ៤,៣% ធៀបនឹង ៥,២% នៅត្រីមាសមុន ក្នុងនេះ កំណើនក្នុងកម្មន្តសាលកម្មថយចុះមកត្រឹម ៦,២% ធៀបនឹង ១៩,២% នៅត្រីមាសមុន។ សេដ្ឋកិច្ចថៃ កើន ០,៤% ក្នុងរយៈពេល១២ខែ ឬ ០,៣ ឯកតាភាគរយ តិចជាងក្នុងត្រីមាសមុន ដោយសារ កម្មន្តសាលកម្មកើន ៣,០% ហើយវិស័យទេសចរណ៍ បានងើបឡើងវិញយ៉ាងខ្លាំង។ កំណើននៅវៀតណាម មានដល់ ៧,៧% ធៀបនឹង ៧,៥% នៅត្រីមាសមុន និងជំរុញឡើងដោយសារការរីកចម្រើនក្នុងកម្មន្តសាលកម្ម ស្របតាមកំណើនខ្លាំងរហូតដល់ ២១,១% ក្នុងការនាំចេញ។

កំណើននៅចិននៅថេរត្រឹម ៦,៨% គឺដូចគ្នានឹងត្រីមាសមុន។ វិស័យមានយូរមកហើយ ដូចជា ឧស្សាហកម្មធុនធ្ងន់ និងអចលនទ្រព្យជាដើម បានថយកំណើន រីឯវិស័យថ្មីៗ ដូចជា សេវាកម្ម និងវិស័យប្រើបច្ចេកវិទ្យាខ្ពស់ បានដំណើរការយ៉ាងល្អ។ សេដ្ឋកិច្ចនៅតំបន់រដ្ឋបាលពិសេស (SAR) ក្រុងហុងកុងនៃប្រទេសចិន កើនឡើង ៣,៤% ធៀបនឹង ៣,៦% នៅត្រីមាសមុន។ សេដ្ឋកិច្ចកូរ៉េខាងត្បូងធ្លាក់ចុះដល់ ២,៩% ធៀបនឹង ៣,៦% នៅត្រីមាសមុន ដោយសារ ចំណាយរបស់គ្រួសារ និងវិនិយោគក្នុងផ្នែកសាងសង់បានថយសន្ទុះ។ ផសស នៅតៃវ៉ាន់ កើន ៣,៣% ក្នុងមួយឆ្នាំ ដែលជាកំណើនខ្ពស់បំផុតគិតតាំងពីឆ្នាំ២០១៤ មក។

តំបន់អឺរ៉ូ មានកំណើនពិត ដល់ ២,៨% ក្នុងត្រីមាសនេះ ធៀបនឹង ២,៥% ក្នុងត្រីមាសមុន។ សេដ្ឋកិច្ចជប៉ុនមានកំណើន ២,០% ធៀបនឹង ១,៧% នៅត្រីមាសមុន ព្រោះមានវិនិយោគខ្លាំងក្នុងវិស័យប្រើបច្ចេកវិទ្យាខ្ពស់ ដូចជាខាងផ្នែកយានយន្ត គ្រឿងអេឡិចត្រូនិក និងម៉ាស៊ីនមានខ្នាតជាក់លាក់កម្រិតខ្ពស់ (precision machinery) ហើយទាំងអស់នេះជំរុញឡើង ដោយសារតម្រូវការក្នុងពិភពលោកនូវ ផលិតផលប្រើបច្ចេកវិទ្យាខ្ពស់។ សេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ដល់ ២,៦% ក្នុងពេលដែល ចំណាយប្រើប្រាស់ និងវិនិយោគក្នុងអាជីវកម្ម មានលក្ខណៈខ្លាំងក្លា។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

ប្រទេសទាំងអស់នៅក្នុងអាស៊ាន និងនៅអាស៊ី សុទ្ធតែមានអតិផរណា។ អតិផរណាមានកម្រិត ២,៣% នៅកម្ពុជា ៣,៤%នៅឥណ្ឌូនេស៊ី ១,៣%នៅម៉ាឡេស៊ី ០,២%នៅសិង្ហបុរី ០,៨%នៅថៃ និង ២,៧%នៅវៀតណាម។ វាមានកម្រិត ២,២%នៅចិន ២,៤%នៅហុងកុង ១,២%នៅកូរ៉េខាងត្បូង និង ១,៦%នៅតៃវ៉ាន់។ អតិផរណាមានកម្រិត ១,៣%នៅតំបន់អឺរ៉ូ ១,៣%នៅជប៉ុន និង ២,២%នៅសហរដ្ឋអាមេរិក។

នៅត្រីមាសទី៤ នេះ អត្រាប្តូរប្រាក់ដុល្លារ-រៀល គឺ ៤.០៣៦ រៀល/ដុល្លារ ដូច្នេះប្រាក់រៀលឡើងថ្លៃ ១,៣% បើធៀបនឹងត្រីមាសមុន។ ប្រាក់បាតថៃឡើងថ្លៃ ១,៥% ដល់ ៣២,៩ បាត/ដុល្លារ ហើយប្រាក់ដុងវៀតណាមឡើងថ្លៃ ០,១% ដល់ ២២.៧១៧.៥ដុង/ដុល្លារ។ ប្រាក់យ័នចិនឡើងថ្លៃ ១,៥% ដល់ ៦,៦យ័ន/ដុល្លារ ហើយប្រាក់យ៉េនជប៉ុនឡើងថ្លៃ ១,៨% ដល់ ១១២,៩យ៉េន/ដុល្លារ។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសនេះ ផលិតផលចម្បងៗភាគច្រើនបានឡើងថ្លៃក្នុងទីផ្សារពិភពលោក លើកលែងតែ ប្រេងដូងប្រេង និងកៅស៊ូដែលបានចុះថ្លៃ។ ប្រេងដូងប្រេងចុះថ្លៃ ០,៥% ដល់ ៧០៣,០ដុល្លារ/តោន ហើយកៅស៊ូចុះថ្លៃ ៥,៥% ដល់ ១.៤៦៦,០ដុល្លារ/តោន។ ពោតឡើងថ្លៃ ០,៥% ដល់ ១៤៨,៨ដុល្លារ/តោន អង្ករឡើងថ្លៃ ២,៦% ដល់ ៤២២,៣ដុល្លារ/តោន សណ្តែកសៀងឡើងថ្លៃ ១,១% ដល់ ៣៩៩,៧ដុល្លារ/តោន។ ប្រេងឆៅឡើងថ្លៃ ១២,៥% ដល់ ៥៩,៤ដុល្លា/ធុង សាំងឡើងថ្លៃ ១,៤% ដល់ ៤៥,០ សេនដុល្លារ/លីត្រ ហើយ ម៉ាស៊ូតឡើងថ្លៃ ៦,៦% ដល់ ៤៨,២ សេនដុល្លារ/លីត្រ។

---

អត្ថបទនេះរៀបរៀងដោយលោក បណ្ឌិត វ៉ើន សីហា ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០១៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.3 | 7.4 | 7.1 | 7.0 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.3 | 5.8 | 5.2 | 4.8 | 4.9 | 5.2 | 5.0 | 4.9 | 5.0 | 5.2 | 5.1 | 5.2 |
| ម៉ាឡេស៊ី | 5.4 | 4.6 | 6.0 | 4.9 | 4.2 | 4.0 | 4.3 | 4.5 | 5.6 | 5.8 | 6.2 | 5.9 |
| សិង្ហបុរី | 1.3 | 3.8 | 3.0 | 2.0 | 1.8 | 2.1 | 1.1 | 2.9 | 2.7 | 2.9 | 5.2 | 4.3 |
| ថៃ | 6.7 | 2.8 | 1.6 | 2.8 | 3.2 | 3.5 | 3.2 | 3.0 | 3.3 | 3.7 | 4.3 | 4.0 |
| វៀតណាម | 5.2 | 5.4 | 5.9 | 6.6 | 5.5 | 3.5 | 6.4 | 6.7 | 5.1 | 6.2 | 7.5 | 7.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.7 | 7.7 | 7.3 | 7.0 | 6.7 | 6.7 | 6.7 | 6.8 | 6.9 | 6.9 | 6.8 | 6.8 |
| ហុងកុង | 2.9 | 3.0 | 2.3 | 2.3 | 0.8 | 1.7 | 1.3 | 3.1 | 4.3 | | 3.6 | 3.4 |
| កូរ៉េខាងត្បូង | 2.1 | 2.8 | 3.4 | 2.6 | 2.7 | 3.2 | 2.3 | 2.3 | 2.8 | 2.7 | 3.6 | 2.9 |
| តៃវ៉ាន់ | 1.2 | 2.2 | 3.5 | 0.6 | -0.8 | 0.7 | 2.0 | 2.9 | 2.6 | 2.1 | 3.1 | 3.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -0.5 | 0.1 | 0.7 | 1.3 | 1.5 | 1.6 | 1.7 | 1.7 | 1.7 | 2.1 | 2.5 | 2.8 |
| ជប៉ុន | 1.7 | 1.7 | 0.6 | 0.3 | 0.2 | 0.8 | 1.1 | 1.6 | 1.6 | 2.0 | 1.7 | 2.0 |
| សហរដ្ឋអាមេរិក | 2.1 | 1.8 | 2.4 | 2.3 | 2.1 | 1.2 | 1.3 | 1.9 | 2.1 | 2.1 | 2.3 | 2.6 |

Sources: International Monetary Fund, *Economist* and countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០១៧ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.0 | 3.0 | 3.9 | 1.2 | 2.4 | 3.1 | 3.0 | 3.6 | 4.2 | 2.7 | 2.5 | 2.3 |
| ឥណ្ឌូនេស៊ី | 4.3 | 7.0 | 6.4 | 6.4 | 4.3 | 3.5 | 3.0 | 3.3 | 3.6 | 4.1 | 3.8 | 3.4 |
| ម៉ាឡេស៊ី | 1.7 | 2.1 | 3.2 | 2.1 | 3.4 | 1.9 | 1.4 | 1.7 | 4.3 | 4.0 | 3.7 | 1.3 |
| សិង្ហបុរី | 4.6 | 2.3 | 1.0 | -0.5 | -0.8 | -0.9 | -1.5 | 0.0 | 0.7 | 0.8 | 0.5 | 0.2 |
| ថៃ | 3.0 | 2.2 | 1.9 | -0.9 | -0.5 | 0.3 | 0.3 | 0.7 | 1.1 | 0.2 | 0.5 | 0.8 |
| វៀតណាម | 9.3 | 6.6 | 4.8 | 0.6 | 1.3 | 2.2 | 2.8 | 4.4 | 5.0 | 0.8 | 2.8 | 2.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.7 | 2.6 | 2.0 | 1.4 | 2.1 | 2.1 | 1.7 | 2.2 | 1.4 | 1.4 | 1.6 | 2.2 |
| ហុងកុង | 4.1 | 4.0 | 4.4 | 3.1 | 2.9 | 2.6 | 3.1 | 1.2 | 1.0 | 2.4 | 1.8 | 2.4 |
| កូរ៉េខាងត្បូង | 2.1 | 1.1 | 1.3 | 0.7 | 0.2 | 0.9 | 0.8 | 1.3 | 2.0 | 2.0 | 2.3 | 1.2 |
| តៃវ៉ាន់ | 1.9 | 0.8 | 1.5 | 0.6 | 1.7 | 1.3 | 0.7 | 1.8 | 0.8 | 0.6 | 0.8 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.5 | 1.4 | 0.4 | 0.0 | 0.1 | 0.2 | 0.3 | 0.7 | 1.8 | 1.2 | 1.4 | 1.3 |
| ជប៉ុន | -0.03 | 0.4 | 2.8 | 0.9 | 0.2 | -0.4 | -0.5 | 0.3 | 0.2 | 0.3 | 1.1 | 1.3 |
| សហរដ្ឋអាមេរិក | 2.1 | 1.5 | 1.6 | 0.0 | 1.1 | 0.7 | 1.1 | 1.9 | 2.5 | 1.9 | 1.9 | 2.2 |

Sources: International Monetary Fund, *Economist* and National Institute of Statistics

តារាង៣៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០១៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4037.8 | 4027.2 | 4037.6 | 4060.4 | 4022.4 | 4056.3 | 4094.1 | 4041.9 | 4015.8 | 4048.2 | 4087.8 | 4036.4 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9363.0 | 10419.2 | 11850.2 | 13394.8 | 13627.3 | 13324.1 | 13136.6 | 13265.3 | 13344.7 | 13312.8 | 13327.0 | 13534.8 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.1 | 3.3 | 3.9 | 4.2 | 4.0 | 4.0 | 4.3 | 4.4 | 4.3 | 4.3 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.2 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 31.1 | 30.7 | 32.5 | 34.2 | 35.6 | 35.3 | 34.8 | 35.4 | 35.1 | 34.3 | 33.4 | 32.9 |
| វៀតណាម (ដុង) | 20856.9 | 20990.3 | 21138.2 | 21917.7 | 22929.4 | 22314.5 | 22292.2 | 22493.7 | 22429.1 | 22704.3 | 22732.8 | 22717.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.3 | 6.1 | 6.2 | 6.3 | 6.5 | 6.5 | 6.7 | 6.8 | 6.9 | 6.9 | 6.7 | 6.6 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1126.6 | 1095.0 | 1053.6 | 1131.9 | 1200.8 | 1163.4 | 1120.9 | 1159.0 | 1152.4 | 1129.9 | 1132.8 | 1107.0 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 29.6 | 29.7 | 30.3 | 31.8 | 33.1 | 32.4 | 31.7 | 31.8 | 31.1 | 30.3 | 30.3 | 30.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.8 |
| ជប៉ុន (យ៉េន) | 79.8 | 97.6 | 105.9 | 121.0 | 115.3 | 107.9 | 102.4 | 109.5 | 113.7 | 111.1 | 110.9 | 112.9 |

Sources: International Monetary Fund, *Economist* and National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១២-២០១៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 298.4 | 259.4 | 192.9 | 169.8 | 160.0 | 171.1 | 153.5 | 152.2 | 160.6 | 157.7 | 148.1 | 148.8 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 999.3 | 856.9 | 821.4 | 622.7 | 586.9 | 647.8 | 714.7 | 753.0 | 773.0 | 696.3 | 706.3 | 703.0 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 3200.7 | 2575.3 | 1755.6 | 1392.7 | 1190.0 | 1408.1 | 1349.4 | 1716.9 | 2147.7 | 1568.1 | 1551.7 | 1466.0 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 594.8 | 533.8 | 434.9 | 395.5 | 385.3 | 465.0 | 430.3 | 376.0 | 537.0 | 431.0 | 411.7 | 422.3 |
| សណ្តែកសៀង (US No.1) - USA (ដុល្លារ/តោន) | 591.4 | 538.4 | 491.8 | 390.4 | 328.0 | 418.7 | 416.7 | 411.7 | 419.1 | 385.7 | 395.3 | 399.7 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 109.5 | 105.9 | 96.2 | 49.6 | 31.2 | 44.7 | 43.3 | 47.9 | 52.0 | 47.9 | 52.8 | 59.4 |
| សាំង - US Gulf Coast (សេន/លីត្រ) | 74.6 | 71.2 | 65.6 | 41.0 | 27.9 | 37.5 | 36.8 | 38.5 | 41.0 | 40.3 | 44.4 | 45.0 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 80.7 | 78.4 | 71.5 | 41.7 | 27.2 | 35.6 | 36.3 | 40.2 | 41.4 | 39.0 | 45.2 | 48.2 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៧ អនុម័តវិនិយោគសរុបគិតជាទ្រព្យសកម្មជាប់លាប់ បានថយចុះដល់ ១១៤,៣លានដុល្លារ ធៀបនឹង ៣.០០៥,៤លានដុល្លារក្នុងត្រីមាសមុន ឬថយចុះ ៧៧,៥% ធៀបនឹងកាលពីមួយឆ្នាំមុន។ ធៀបនឹងត្រីមាសមុន វិនិយោគក្នុងគ្រប់វិស័យបានធ្លាក់ចុះជាខ្លាំង ដោយក្នុងគ្រប់វិស័យមិនមានការធ្វើវិនិយោគទេ លើកលែងតែក្នុង ឧស្សាហកម្ម។ អនុម័តវិនិយោគសរុបក្នុងវិស័យឧស្សាហកម្ម មានត្រឹម ១១៤,៣ លានដុល្លារ ធៀបនឹង ៤៨៦,៦លានដុល្លារ ក្នុងត្រីមាសមុន។ ដោយឡែកវិនិយោគក្នុងផ្នែកកាត់ដេរ បានធ្លាក់ចុះពី ៧៨,៩ លានដុល្លារ ក្នុងត្រីមាសមុន មកត្រឹម ៥៦,៣លានដុល្លារ។

ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិមកដល់សរុប កើនដល់ ១.៦៨៩.៤០០នាក់ ធៀបនឹង ១.១៤៧.៥០០នាក់ កាលពីមួយឆ្នាំមុន។ ភ្ញៀវទេសចរចិនមានច្រើនជាងគេ ពោលគឺ ក្នុងត្រីមាសនេះ មានដល់ ៣៦៩.៤០០នាក់ បន្ទាប់មកទៀតគឺ ទេសចរមកពីវៀតណាមមាន ២៤១.៩០០នាក់ មកពីថៃ ១៥២.១០០នាក់ ពីកូរ៉េខាងត្បូង ៨៨.៦០០នាក់ សហរដ្ឋអាមេរិក ៧១.១០០នាក់ ជប៉ុន ៥៦.៤០០នាក់ ម៉ាឡេស៊ី ៥៦.៤០០នាក់ បារាំង ៤៧.៧០០នាក់ ចក្រភពអង់គ្លេស ៤៧.៧០០នាក់។

ក្នុងត្រីមាសនេះ ការនាំចេញសរុបមានដល់ ២.៨២៥,៦លានដុល្លារ ឬថយចុះ ៨,៨% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ១៥,១% ធៀបនឹងមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ថយចុះ ១៤,៤% ធៀបនឹងត្រីមាសមុន ដល់ ១.៩៦០,០លានដុល្លារ ប៉ុន្តែកើន ១១,៥% ធៀបនឹងមួយឆ្នាំមុន។ ធៀបនឹងត្រីមាសមុន ការនាំចេញសម្លៀកបំពាក់ទៅសហភាពអឺរ៉ុប ជប៉ុន ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងប្រទេសឯទៀតក្នុងពិភពលោក បានធ្លាក់ចុះ លើកលែងតែការនាំចេញទៅបណ្តាប្រទេសអាស៊ាន ដែលបានកើនឡើង។ ការនាំចេញគ្រឿងបង្គុំអេឡិចត្រូនិក មានដល់ ៩៦,៩លានដុល្លារ ឬ ខ្ពស់ជាងត្រីមាសមុន ១៧,៩%។ ការនាំចេញគ្រឿងបង្គុំយានយន្ត កើនដល់ ១,៨លានដុល្លារ ធៀបនឹង ១,១លានដុល្លារក្នុងត្រីមាសមុន។

ការនាំចេញផលិតផលកសិកម្ម កើន ៦,០% ធៀបនឹងត្រីមាសមុន ដល់ ១៨៥,៩លានដុល្លារ ឬកើន ៣,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ធៀបនឹងត្រីមាសមុន ការនាំចេញអង្ករ ឈើ ត្រី កើនឡើង រីឯការនាំចេញកៅស៊ូបានថយចុះ។

ការនាំចូលសរុប ធ្លាក់ចុះ ២០,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ១១,១% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ៣.៤២៤,២ លានដុល្លារ។ ការនាំចូលសាំង មានតម្លៃ ៦៥,៨លានដុល្លារ ម៉ាស៊ូត ១០២,២លានដុល្លារ សម្ភារសំណង់ ៦៨,៨លានដុល្លារ និងការនាំចូលផ្សេងទៀត ៣.១៨៧,៥លានដុល្លារ។ ក្នុងត្រីមាសនេះ កម្ពុជាមានឱនភាពពាណិជ្ជកម្ម ៥៩៨,៧លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

ក្នុងត្រីមាសទី៤ នេះ ថវិការបស់រដ្ឋាភិបាលមានឱនភាព ១.២៨៤,៨ប៊ីលានរៀល។ ចំណូលសរុបរបស់រដ្ឋាភិបាល មានដល់ ៤.៣០៧,២ប៊ីលានរៀល ឬ ១១,៣% ច្រើនជាងត្រីមាសមុន និង ២៦,២% ច្រើនជាងក្នុងត្រីមាសដូចគ្នាឆ្នាំមុន។ ចំណូលចរន្តមានដល់ ៤.២៧៨,៥ប៊ីលានរៀល ឬ ១១,៤% ច្រើនជាងត្រីមាសមុន។ ចំណូលពន្ធ មានដល់ ៣.៥០០,០ប៊ីលានរៀល ឬ ៥,៥% ច្រើនជាងត្រីមាសមុន ហើយចំណូលមិនមែនពន្ធ មានដល់ ៧៧៨,៥ប៊ីលានរៀល ឬ ៤៩,៥% ច្រើនជាងត្រីមាសមុន។

ចំណាយសរុប មានដល់ ៥.៥៩១,៩ប៊ីលានរៀល ឬ ២៦,៥% ច្រើនជាងត្រីមាសមុន និង ៦១,៦% ច្រើនជាងក្នុងត្រីមាសដូចគ្នាឆ្នាំមុន។ ចំណាយមូលធន មានដល់ ១.៧៨៥,៩ប៊ីលានរៀល ឬ ៤៨,៦% ច្រើនជាងត្រីមាសមុន។ ចំណាយចរន្ត មានដល់ ៣.៨០៦,០ប៊ីលានរៀល ឬ ១៨,២% ច្រើនជាងត្រីមាសមុន។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០១៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប (CPI) មានកម្រិត ២,២% ធៀបនឹង ២,៥% នៅត្រីមាសមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រាបានកើនឡើង ១,៩% ឬ ០.៦ឯកតាភាគរយ ទាបជាងត្រីមាសមុន។ ថ្លៃដឹកជញ្ជូនកើន ៤,១% ពីមួយឆ្នាំទៅមួយឆ្នាំ។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលចុះថ្លៃ ១,៣% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៣៦,៤រៀល/ដុល្លារ និងចុះថ្លៃ ១,១% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៩រៀល/១០០ដុង។ ប្រាក់រៀលឡើងថ្លៃ ០,៥% ទល់នឹងប្រាក់បាតថៃ ដល់ ១២៣,៤រៀល/បាត។

មាសឡើងថ្លៃ ០,៩% ដល់ ១៥៥,៥ដុល្លារ/ជី។ ម៉ាស៊ូតឡើងថ្លៃ ៣,១% ដល់ ៣.៤៧២,៤រៀល/លីត្រ ហើយ សាំងឡើងថ្លៃ ២,៦% ដល់ ៣.៨១៩,៧/លីត្រ។

## ស្ថានភាពក្រីក្រ

ផ្នែកនេះពិពណ៌នាពីស្ថានភាពរបស់ ពលករងាយរងគ្រោះ និងកម្មករកាត់ដេរ ដោយផ្អែកតាមអង្កេតលើពលករងាយរងគ្រោះ ៣២០នាក់ និងកម្មករកាត់ដេរ ១២០នាក់ ក្នុងខែកុម្ភៈ។

ប្រាក់កម្រៃប្រចាំថ្ងៃរបស់កម្មករកាត់ដេរកើន២,៥%ធៀបនឹងឆ្នាំមុន ដល់ ១៥.២៦៨រៀល។ ពួកគេមានអាយុជាមធ្យម ២៩ឆ្នាំ និងមានកម្រិតអប់រំជាមធ្យមដល់ថ្នាក់ទី៥។ ជាទូទៅ ពួកគេធ្វើការ

---

អត្ថបទនេះ រៀបរៀងដោយបណ្ឌិត ជីន សីហា ជាអ្នកស្រាវជ្រាវ និង ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

ក្នុងរោងចក្របានប្រមាណ ៤ឆ្នាំមកហើយ។ ក្នុងនេះមាន ៧២,៥% និយាយថា ខ្លួនមិនបានទទួលការបណ្តុះបណ្តាលជំនាញអ្វីទេមុនពេលចូលធ្វើការនេះ គឺទទួលបានការបណ្តុះបណ្តាលនៅក្នុងរោងចក្រតែម្តង។ មាន ៤,២% ទៀតនិយាយថា គាត់បានបណ្តុះបណ្តាលខ្លួនឯងនៅឯផ្ទះ ហើយ ២៣,៣% ប្រាប់ថា មិនដែលទទួលបានការបណ្តុះបណ្តាលអ្វីទេ។ តបនឹងសំណួរថា តើប្រាក់កម្រៃប្រចាំថ្ងៃរបស់ខ្លួនអាចផ្គត់ផ្គង់គ្រួសារបានឬទេ? គឺមាន ១៥,០% ឆ្លើយថា មិនអាចផ្គត់ផ្គង់គ្រួសារបានទេ, ៨១,៦% ឆ្លើយថា អាចផ្គត់ផ្គង់បានមួយភាគ ហើយ ៣,៣% ឆ្លើយថា អាចផ្គត់ផ្គង់គ្រួសារបាន។ ម៉្យាងទៀត មាន ៦៧,៥% មានសុទិដ្ឋិនិយមចំពោះអនាគតរោងចក្ររបស់ខ្លួន, ៧,៥% និយាយថា អនាគតរោងចក្រមិនសូវល្អទេ, ៥,៨% និយាយថា គ្មានការប្រែប្រួល ហើយក្រៅពីនោះ គ្មានយោបល់ទេ។

ប្រាក់ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើនដល់ ៨.៧៧៤ រៀល/ថ្ងៃ ឬ ៥,៣% ខ្ពស់ជាងកាលពីមួយឆ្នាំមុន។ អ្នកឆ្លើយសម្ភាស៍ ៧៥,០% ជាអ្នករកចំណូលចម្បងសម្រាប់គ្រួសារខ្លួន និងមាន ៧៥,០% ដែរដែលបានប្រាប់ថា ប្រាក់ចំណូលគាត់បានធ្លាក់ចុះធៀបនឹងត្រីមាសមុន។ ក្នុងចំណោមអ្នកឆ្លើយសម្ភាស៍មានពាក់កណ្តាលបានប្រាប់ថា ប្រាក់ចំណូលរបស់ខ្លួន ក្នុងខែកុម្ភៈ អាចផ្គត់ផ្គង់គ្រួសារបានមួយភាគ ហើយពាក់កណ្តាលទៀតនិយាយថា មិនអាចផ្គត់ផ្គង់បានទេ។ ម៉្យាងទៀតមាន ៤៧,៥% កំពុងជាប់បំណុលដែលមានអត្រាការប្រាក់ជាមធ្យម ១,៦% ក្នុងមួយខែ។

អ្នកលក់បន្លែតូចតាច មានប្រាក់ចំណូលថយចុះ ដល់ ១៨.៣៤៣រៀល/ថ្ងៃ ឬ ០,៤% ទាបជាងកាលពីមួយឆ្នាំមុន។ ពួកគេភាគច្រើនមកពីខេត្តកណ្តាល ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ តាកែវ កំពត កំពង់ចាម និងមកពីក្រុងភ្នំពេញ។ ពួកគេ ១៥% មិនមានដីកសិកម្មទេ, ២,៥% មានដីតិចជាង ០,៥ហិកតា, ៣០,០% មានដីពី ០,៥ ទៅ ១ហិកតា និង ៥២,៥% មានដីចាប់ពី ១ហិកតាដល់ក្រោម ២ហិកតា។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាជាអ្នករកប្រាក់ចំណូលចម្បងក្នុងគ្រួសារ និងមាន ៤០,០% ប្រាប់ថា កំពុងជំពាក់បំណុលគេ។

អ្នករើសអេតចាយមានប្រាក់ចំណូលថយចុះ ៧,១% ធៀបនឹងឆ្នាំមុន ដល់ ១០.៦៦៤រៀល/ថ្ងៃ។ ធៀបនឹងបីខែមុន ចំនួនអ្នករើសអេតចាយបានកើនឡើង ប៉ុន្តែប្រភពសំរាម និងថ្លៃរបស់អេតចាយ បានធ្លាក់ចុះ បើតាមសំដីរបស់អ្នកឆ្លើយសម្ភាសន៍ភាគច្រើន។ អ្នករើសអេតចាយឆ្លើយសម្ភាស៍ ៩២,៥% ជាអ្នករកចំណូលចិញ្ចឹមគ្រួសារ។ ជាមធ្យម អ្នករើសអេតចាយធ្វើការ ១០,៧ម៉ោង/ថ្ងៃ និង ២៧,៤ថ្ងៃ/ខែ។ ពួកគេចំណាយជាសំខាន់លើស្បៀងអាហារ (ជាធ្យម ៦៨,៣% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ(១៧,៧%)ការថែទាំសុខភាព(០,៨%) និងចំណាយផ្សេងទៀត (១៣,២%)។

កម្មករសំណង់មិនជំនាញ មានចំណូលប្រចាំថ្ងៃកើនឡើង ៨,៥% ធៀបនឹងមួយឆ្នាំមុន ដល់ ១៨.០៨២រៀល/ថ្ងៃ។ ធៀបនឹងបីខែមុន កម្មករភាគច្រើននិយាយថា ចំនួនកម្មករសំណង់មិនជំនាញ បានកើនឡើង ទន្ទឹមគ្នានឹងកំណើនក្នុងសកម្មភាពសាងសង់។ កម្មករ ៨៧,៥% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកធ្វើការនៅក្រុងភ្នំពេញ ឬសៀមរាប ហើយ ១២,៥% បានធ្វើចំណាកស្រុកជាមួយគ្រួសារ។ ពួកគេធ្វើការ ៩,៣ម៉ោង/ថ្ងៃ និង ២៤,៤ថ្ងៃ/ខែ ជាមធ្យម។ ក្នុងចំណាយសរុបរបស់កម្មករ មាន ៧៤,៣% ជាចំណាយលើស្បៀងអាហារ ១៣,៩% ជាចំណាយលើថ្លៃឈ្នួលកន្លែងស្នាក់នៅ ០,៣% ជាចំណាយលើការថែទាំសុខភាព និង ១១,៥% ជាចំណាយផ្សេងៗទៀត។ កម្មករ ៩២,៥% និយាយថា ចំណូលរបស់ខ្លួនអាចផ្គត់ផ្គង់គ្រួសារបានតែមួយភាគប៉ុណ្ណោះ។

ចំណូលរបស់អ្នកលីសែងធ្លាក់ចុះ ០,៣% ដល់ ១៥.១២៣ រៀល/ថ្ងៃ ធៀបនឹងខែដូចគ្នាឆ្នាំមុន។ កម្មករ ៧២,៥% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកធ្វើការនៅក្រុងភ្នំពេញ ឬសៀមរាប ហើយ ២៧,៥% ធ្វើចំណាកស្រុកជាមួយគ្រួសារ។ ចំណូលភាគច្រើនរបស់អ្នកលីសែង បានយកទៅចំណាយលើ ស្បៀងអាហារ (៧៤,១% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (១៦,២%) ការថែទាំសុខភាព (០,៣%) និងចំណាយផ្សេងៗទៀត (៩,៤%)។ អ្នកឆ្លើយសម្ភាស៍ ៦៧,៥% ប្រាប់ថា តាំងពីពេលចាប់ធ្វើការជាអ្នកលីសែងមក គ្រួសាររបស់គាត់មានជីវភាពប្រសើរឡើង, ២៥,០% និយាយថា ជីវភាពគ្រួសារនៅដដែល ហើយ ៧,៥% ប្រាប់ថា គ្រួសារគាត់មានជីវភាពកាន់តែលំបាកឡើង។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់តុភោជនីយដ្ឋាន កើន ៤,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ៨.២២៦រៀល/ថ្ងៃ។ ពួកគេធ្វើការជាអ្នករត់តុជាមធ្យម ៤,៧ឆ្នាំមកហើយ និងត្រូវធ្វើការជាមធ្យម ១២,៤ម៉ោង/ថ្ងៃ និង ៣០ថ្ងៃ/ខែ។ ក្នុងចំណាយសរុបរបស់គាត់មាន ៧៩,១% ជាចំណាយលើស្បៀងអាហារ ៤,៧% លើការថែទាំសុខភាព និង ១៥,២% ជាចំណាយផ្សេងៗទៀត។

# តាមដានសេដ្ឋកិច្ច - សូចនាករសេដ្ឋកិច្ច

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១២-១៧ *

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 531.6 | 930.5 | 56.5 | 169.8 | 27.6 | 0.0 | 7.4 | 82.1 | 8.0 | 54.9 | - | - |
| ឧស្សាហកម្ម | 829.3 | 3257.0 | 1002.5 | 1014.7 | 252.4 | 597.0 | 266.1 | 320.8 | 115.6 | 265.7 | 486.6 | 114.3 |
| *. កាត់ដេរ* | 497.0 | 324.1 | 393.5 | 225.2 | 70.8 | 239.9 | 51.1 | 19.0 | 54.0 | 22.0 | 78.88 | 56.3 |
| សេវាកម្ម | 916.6 | 140.7 | 622.6 | 2734.4 | 643.6 | 234.1 | 681.9 | 104.6 | 7.8 | 1332.0 | 2518.8 | 0 |
| *. សណ្ឋាគារ និងទេសចរ* | 691.5 | 106.0 | 446.9 | 98.6 | 611.1 | 19.8 | 679.8 | 56.3 | 3.6 | 237.2 | 2518.8 | 0 |
| សរុប | 2278.0 | 4328.0 | 1583.9 | 3918.9 | 923.7 | 831.2 | 955.5 | 507.4 | 131.4 | 1652.6 | 3005.4 | 114.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 80.5 | -10.0 | 15.0 | -46.9 | -74.1 | 1158.0 | 81.9 | -96.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -67.5 | 90.1 | 63.4 | 147.4 | -67.9 | 226.4 | 242.0 | -0.8 | -85.8 | 98.8 | 214.5 | -77.5 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១២-១៧

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 333.9 | 463.1 | 560.3 | 694.7 | 217.2 | 161.5 | 198.6 | 252.7 | 273.0 | 362.0 | 206.4 | 369.4 |
| វៀតណាម | 763.1 | 854.1 | 905.8 | 987.8 | 217.6 | 244.2 | 233.9 | 264.0 | 203.4 | 267.3 | 122.8 | 241.9 |
| កូរ៉េខាងត្បូង | 411.5 | 435.0 | 424.4 | 395.3 | 131.5 | 61.5 | 70.9 | 93.3 | 127.7 | 87.7 | 41.1 | 88.6 |
| ថៃ | 201.4 | 221.3 | 279.5 | 349.9 | 85.7 | 82.2 | 87.8 | 142.4 | 95.9 | 99.5 | 47.5 | 152.1 |
| សហរដ្ឋអាមេរិក | 173.1 | 185.0 | 191.4 | 217.5 | 75.7 | 50.5 | 44.0 | 68.5 | 80.1 | 76.2 | 29.2 | 71.1 |
| ជប៉ុន | 179.3 | 206.9 | 215.8 | 193.3 | 55.8 | 35.1 | 46.7 | 54.0 | 60.2 | 51.4 | 35.3 | 56.4 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បារាំង | 121.2 | 131.5 | 141.1 | 145.7 | 48.7 | 25.8 | 32.3 | 43.6 | 54.0 | 43.2 | 21.5 | 47.7 |
| ចក្រភពអង់គ្លេស | 110.2 | 123.9 | 133.3 | 154.3 | 51.6 | 31.3 | 33.1 | 43.5 | 54.6 | 48.2 | 20.6 | 47.7 |
| ម៉ាឡេស៊ី | 116.8 | 130.7 | 144.4 | 149.4 | 53.0 | 17.5 | 39.3 | 43.1 | 37.8 | 53.4 | 31.8 | 56.4 |
| ផ្សេងៗ | 1173.8 | 1458.7 | 1506.8 | 1487.3 | 405.7 | 406.6 | 360.9 | 498.2 | 516.2 | 70.9 | 693.9 | 558.1 |
| តាមផ្លូវអាកាស | 1722.1 | 2017.7 | 2273.5 | 2476.0 | 785.0 | 593.5 | 602.2 | 797.4 | 921.4 | 684.3 | 777.7 | 929,3 |
| តាមផ្លូវគោក និងទឹក | 1862.2 | 2192.5 | 2229.3 | 2299.2 | 557.4 | 522,7 | 545,3 | 705.9 | 581.5 | 475.5 | 472.3 | 760,1 |
| សរុប | 3584.3 | 4210.2 | 4502.8 | 4775.2 | 1342.5 | 1116.2 | 1147.5 | 1503.3 | 1502.9 | 1159.8 | 1250.1 | 1689,4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -0.6 | -16.9 | 2.8 | 47.6 | -0.03 | -22.8 | 7.3 | 35,1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 24.4 | 17.5 | 7.0 | 6.1 | -2.4 | 12.3 | 9.8 | 5.2 | 11.9 | 3.9 | 22.7 | 12,4 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១២-១៧ *

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 6106.4 | 6982.4 | 8106.0 | 9256.4 | 2388.3 | 2383.4 | 2817.7 | 2454.0 | 2290.7 | 2626.9 | 3098.3 | 2825.6 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 5015.4 | 5386.1 | 5960.5 | 6827.0 | 1759.4 | 1717.8 | 2072.5 | 1758.2 | 1856.3 | 1874.1 | 2290.3 | 1960.0 |
| - សហរដ្ឋអាមេរិក | 2143.3 | 2075.2 | 1963.6 | 2009.4 | 423.1 | 440.4 | 554.5 | 413.5 | 452.3 | 426.0 | 570.8 | 474.7 |
| - សហភាពអឺរ៉ុប | 1716.9 | 1969.6 | 2403.7 | 2903.9 | 789.6 | 776.6 | 733.4 | 629.2 | 583.0 | 693.3 | 787.9 | 718.1 |
| - អាស៊ាន | 39.4 | 60.2 | 83.3 | 103.4 | 25.6 | 25.7 | 21.4 | 25.7 | 24.2 | 29.0 | 24.2 | 29.6 |
| - ជប៉ុន | 188.6 | 278.7 | 383.1 | 524.2 | 176.0 | 122.5 | 216 | 141.0 | 196.2 | 136.7 | 204.8 | 163.6 |
| - ចក្រភពអង់គ្លេស | - | - | - | - | - | - | 251.8 | 188.0 | 214.2 | 201.6 | 267.0 | 221.2 |
| - ប្រទេសផ្សេងៗ | 927.2 | 1002.9 | 1126.8 | 1286.3 | 345.2 | 352.7 | 547.1 | 548.9 | 600.6 | 589.2 | 702.7 | 613.7 |
| គ្រឿងអេឡិចត្រូនិច | - | - | - | - | - | - | - | - | 127.1 | 73.9 | 82.2 | 96.9 |
| គ្រឿងយន្ត | - | - | - | - | - | - | - | - | 1.8 | 6.9 | 1.1 | 1.8 |
| កសិកម្ម | 376.7 | 554.5 | 624.4 | 548.8 | 137.5 | 98.9 | 118.1 | 179.5 | 201.0 | 144.2 | 175.4 | 185.9 |
| - កៅស៊ូ | 176.6 | 175.2 | 153.9 | 165.4 | 30.7 | 26.8 | 48.3 | 59.6 | 66.1 | 65.2 | 71.7 | 70.5 |
| - ឈើ | 36.8 | 73.6 | 132.0 | 46.3 | 4.9 | 12.4 | 11.6 | 18.3 | 11.7 | 28.9 | 24.6 | 35.3 |
| - ត្រី | 2.0 | 1.2 | 0.8 | 0.5 | 0.2 | 0.1 | 0.2 | 0.2 | 0.2 | 0.1 | 0.1 | 0.2 |
| - អង្ករ | 146.4 | 262.3 | 248.5 | 315.3 | 91.4 | 56.1 | 53.4 | 99.9 | 83.1 | 35.0 | 66.5 | 70.5 |
| - ផលិតផលកសិកម្មផ្សេងៗ | 14.9 | 42.4 | 89.1 | 21.3 | 10.3 | 3.6 | 4.6 | 1.6 | 39.9 | 15.0 | 12.4 | 9.4 |
| *Others* | 714.4 | 1088.2 | 1520.1 | 1880.2 | 491.3 | 566.6 | 627.1 | 516.2 | 233.4 | 608.6 | 632.6 | 640.1 |
| ការនាំចូលសរុប | 8593.3 | 8639.4 | 10295.4 | 11494.5 | 2784.7 | 6136.6 | 3017.0 | 3080.8 | 3173.5 | 5914.4 | 4303.3 | 3424.2 |
| ក្នុងនេះ៖ | | | | | | | | | | | | |
| - សាំង | 308.0 | 306.4 | 334.7 | 377.3 | 95.4 | 99.2 | 93.3 | 97.1 | 75.1 | 57.5 | 58.3 | 65.8 |
| - ម៉ាស៊ីន | 559.5 | 569.1 | 602.3 | 607.8 | 163.1 | 194.6 | 173.7 | 178.0 | 146.4 | 111.1 | 113.3 | 102.2 |
| - សម្ភារសំណង់ | 66.1 | 80.8 | 117.6 | 164.4 | 50.8 | 62.1 | 83.1 | 57.4 | 55.6 | 90.3 | 89.6 | 68.8 |
| ផ្សេងៗ | 7659.1 | 7682.6 | 9240.7 | 10345.1 | 2475.0 | 5780.8 | 2667.0 | 2748.4 | 2896.4 | 5655.5 | 4042.2 | 3187.5 |
| ជញ្ជីងពាណិជ្ជកម្ម | -1341.6 | -1610.9 | -2184.3 | -2238.1 | -390.7 | -3753.3 | -199.4 | -626.8 | 882.8 | -3287.6 | -1205.0 | -598.7 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | 4.7 | -2.4 | 20.6 | -15.2 | 5.6 | 1.0 | 22.2 | -12.7 |
| ការនាំចេញសរុប | - | - | - | - | 3.4 | -0.2 | 18.2 | -12.9 | -6.7 | 14.7 | 17.9 | -8.8 |
| ការនាំចូលសរុប | - | - | - | - | -5.8 | 120.8 | -50.8 | 2.1 | 3.0 | 86.4 | -27.2 | -20.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 17.7 | 7.4 | 10.7 | 14.5 | 13.6 | 7.2 | 3.9 | 4.6 | 5.5 | 9.1 | 10.5 | 13.7 |
| ការនាំចេញសរុប | 16.1 | - | - | 14.2 | 10.1 | 9.2 | 8.6 | 6.3 | -4.1 | 10.2 | 10.0 | 15.1 |
| ការនាំចូលសរុប | 19.7 | 21.4 | 19.2 | 11.7 | 5.0 | 2.5 | 110.1 | 3.8 | 14.2 | -3.6 | 42.6 | 11.1 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (web site)

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១២-១៧ (ប៊ីលានរៀល)

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 7691.9 | 8255.2 | 10543.4 | 11879.9 | 3533.1 | 3849.7 | 3413.7 | 3405.0 | 4261.9 | 4093.6 | 3870.8 | 4307.2 |
| ចំណូលចរន្ត | 7443.8 | 8233.2 | 10359.4 | 11759.0 | 3514.7 | 3836.3 | 3375.9 | 3361.7 | 3261.9 | 4071.5 | 3839.2 | 4278.5 |
| ចំណូលពន្ធ | 6334.8 | 7198.1 | 8995.2 | 10502.4 | 3255.5 | 3368.1 | 2850.5 | 2722.4 | 3905.8 | 3580.5 | 3318.4 | 3500.0 |
| ពន្ធក្នុងស្រុក | 5002.8 | 5728.1 | 7226.5 | 8591.7 | 2715.3 | 2854.5 | 2378.5 | 2237.4 | 2450.0 | 3107.5 | 2844.0 | 2928.3 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1331.7 | 1470.0 | 1822.7 | 1910.7 | 540.1 | 513.6 | 472.0 | 485.0 | 455.8 | 473.1 | 474.4 | 471.8 |
| ចំណូលមិនមែនពន្ធ | 1118.2 | 1035.2 | 1310.3 | 1256.6 | 259.3 | 468.2 | 525.4 | 639.4 | 356.2 | 490.9 | 520.9 | 778.5 |
| ចំណូលលើទ្រព្យសម្បត្តិ | 143.0 | 84.0 | 88.5 | 77.3 | 8.1 | 26.1 | 43.2 | 38.5 | 17.4 | 35.8 | 39.1 | 34.9 |
| លក់ទំនិញ និងសេវា | 667.4 | 750.3 | 871.2 | 1047.1 | 198.5 | 315.3 | 294.9 | 439.5 | 272.1 | 360.3 | 347.3 | 537.0 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.8 | 200.8 | 350.5 | 132.2 | 52.7 | 126.8 | 187.3 | 161.3 | 66.6 | 94.8 | 134.7 | 206.5 |
| ចំណូលជាមូលធន | 247.9 | 73.4 | 184.0 | 121.0 | 18.3 | 13.4 | 38.4 | 43.3 | 0.0 | 22.1 | 31.5 | 28.7 |
| ចំណាយសរុប | 9660.9 | 12535.7 | 13306.5 | 13849.5 | 2364.3 | 3405.3 | 3460.8 | 4509.2 | 3090.9 | 3878.4 | 4420.9 | 5591.9 |
| ចំណាយជាមូលធន | 3628.3 | 5567.5 | 5590.7 | 5290.3 | 620.9 | 1091.1 | 811.3 | 1225.6 | 859.0 | 1096.0 | 1202.1 | 1785.9 |
| ចំណាយចរន្ត | 6188.4 | 6968.3 | 7715.8 | 8544.6 | 1743.4 | 2314.2 | 2649.1 | 3283.6 | 2231.9 | 2782.4 | 3218.7 | 3806.0 |
| បៀវត្សរ៍ | 2486.6 | 2997.3 | 3755.5 | 4271.9 | 1133.1 | 1418.3 | 1403.6 | 1426.7 | 1567.6 | 1515.7 | 1739.3 | 1820.2 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1586.8 | 1563.0 | 1627.0 | 1742.9 | 259.1 | 439.7 | 447.5 | 628.7 | 312.9 | 635.2 | 617.0 | 749.6 |
| ចំណាយចរន្តផ្សេងទៀត | 2115.1 | 2408.0 | 2333.4 | 2529.8 | 351.2 | 456.2 | 798.1 | 1228.2 | 664.3 | 1266.7 | 1479.5 | 1983.8 |
| សមតុល្យជាទូទៅ | -1969.0 | -4280.6 | -2763.1 | -1969.6 | 1168.8 | 444.4 | -47.0 | -1104.2 | 1171.1 | 215.2 | -550.1 | -1284.8 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2457.8 | 4326.2 | 3972.1 | 3729.4 | 266.4 | 775.6 | 141.0 | 661.9 | 598.5 | 960.8 | 640.6 | 894.1 |
| ហិរញ្ញប្បទានក្នុងស្រុក | -332.9 | 824.4 | -1428.7 | -2034.9 | -1631.4 | -488.5 | 37.5 | 342.7 | -352.8 | -339.1 | 88.8 | 82.9 |

Source: MEF website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១២-១៧

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 2.3 | 3.0 | 3.9 | 1.2 | 2.5 | 3.0 | 3.0 | 3.9 | 4.2 | 2.7 | 2.5 | 2.2 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 2.5 | 3.9 | 4.9 | 4.0 | 4.7 | 6.2 | 5.5 | 6.0 | 6.0 | 3.1 | 2.7 | 1.9 |
| - ដឹកជញ្ជូន | 3.3 | -0.6 | -1.0 | -9.2 | -6.5 | -9.9 | -7.9 | -3.4 | 4.1 | 4.3 | 3.8 | 4.1 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4039.2 | 4036.2 | 4060.4 | 4060.4 | 4022.4 | 4056.3 | 4094.1 | 4041.9 | 4015.8 | 4048.2 | 4089.5 | 4036.4 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| រៀលក្នុង ១ បាតថៃ | 130.0 | 124.9 | 119.4 | 119.4 | 113.4 | 115.7 | 118.1 | 114.9 | 114.9 | 118.8 | 122.8 | 123.402 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.4 | 19.1 | 18.7 | 18.7 | 18.1 | 18.3 | 18.5 | 18.1 | 17.8 | 17.9 | 18.1 | 17.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 200.9 | 175.9 | 152.3 | 140.6 | 151.2 | 151.2 | 157.1 | 148.3 | 145.5 | 150.9 | 154.1 | 155.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4941.2 | 4852.1 | 4934.1 | 3771.3 | 2903.8 | 2932.8 | 3050.2 | 3129.3 | 3391.6 | 3310.4 | 3369.0 | 3472.4 |
| ថ្លៃសាំង (រៀល/លីត្រ) | 5312.7 | 5083.3 | 5155.7 | 3951.7 | 3310.6 | 3318.2 | 3281.4 | 3437.1 | 3697.0 | 3625.2 | 3722.0 | 3819.7 |

Sources: NIS, NBC and CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១២-១៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 18154.5 | 21260.1 | 26699.7 | 26665.5 | 29247.8 | 30138.5 | 32188.4 | 32814.5 | 36490.5 | 40285.4 | 43301.5 | 42575.3 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 10437.4 | 11508.3 | 15859.8 | 22157.6 | 21643.0 | 24399.1 | 24939.2 | 25802.3 | 24057.0 | 24985.6 | 26440.4 | 28743.5 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2486.4 | -2794.9 | -4359.1 | -6428.8 | -7621.2 | -7977.4 | -7916.6 | -8148.5 | -9818.9 | -10128.0 | -10347.7 | -11066.5 |
| ឥណទានដល់វិស័យឯកជន | 23536.6 | 27608.8 | 36244.6 | 46071 | 47627.0 | 52528.6 | 54551.1 | 56458.8 | 57385.9 | 61189.9 | 63492.6 | 66922.6 |
| រូបិយវត្ថុទូទៅ M2 | 28591.9 | 32768.4 | 42559.5 | 48823.1 | 50890.9 | 54537.6 | 57127.5 | 57616.8 | 60547.4 | 65271.0 | 69741.9 | 71318.9 |
| រូបិយវត្ថុ M1 | 4045.7 | 4878.2 | 6308.4 | 6741.4 | 6717.8 | 6872.0 | 7460.9 | 7273.0 | 7524.7 | 8186.1 | 8925.0 | 9428.4 |
| រូបិយវត្ថុផ្សេងៗ | 18154.5 | 21260.1 | 26699.7 | 42081.7 | 44173.1 | 47665.6 | 49666.6 | 53022.7 | 53022.7 | 57084.8 | 60816.9 | 61890.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 20.9 | 14.6 | 29.9 | 14.7 | 16.5 | 18.2 | 21.7 | 18.0 | 19.0 | 19.7 | 22.1 | 23.8 |
| រូបិយវត្ថុ M1 | 2.3 | 20.6 | 29.3 | 6.9 | 1.4 | 9.2 | 18.7 | 7.9 | 12.2 | 19.1 | 19.6 | 29.6 |
| រូបិយវត្ថុផ្សេងៗ | 44.6 | 13.6 | 30.0 | 16.1 | 19.2 | 19.6 | 22.1 | 19.6 | 20.0 | 19.8 | 22.5 | 22.9 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយ ធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2013 | 2014 | 2015 | 2016 | 2017 | | | | 2018 | 2017 | | 2018 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នករត់ស៊ីក្លូ | 10438 | 10774 | 12405 | 11516 | 11092 | 10916 | 10804 | 10362 | 11042 | -4.4 | -7.5 | -0.4 |
| អ្នកលីសែង | 13247 | 13580 | 15631 | 14318 | 15171 | 14625 | 15423 | 14549 | 15123 | 9.4 | 7.7 | -0.3 |
| អ្នកលក់បន្លែតូចតាច | 11366 | 14751 | 15867 | 17177 | 18411 | 13980 | 19655 | 16015 | 18343 | 65.1 | -8.4 | -0.4 |
| អ្នករើសអេតចាយ | 9819 | 9173 | 12344 | 10297 | 11478 | 12428 | 11754 | 10703 | 10664 | 18.1 | -5.7 | -7.1 |
| អ្នករត់តុភោជនីយដ្ឋាន* | 6697 | 7789 | 8436 | 7989 | 7905 | 8141 | 8135 | 8190 | 8226 | 3.0 | 2.2 | 4.1 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 6599 | 7514 | 8745 | 8088 | 8332 | 7049 | 8708 | 8132 | 8774 | 12.8 | -1.2 | 5.3 |
| កម្មកររោងចក្រកាត់ដេរ | 10161 | 11178 | - | 13688 | 14889 | 12910 | 14299 | 14275 | 15268 | 10.8 | 8.7 | 2.5 |
| អ្នករត់ម៉ូតូឌុប | 13450 | 13386 | 14455 | 14509 | 14770 | 13888 | 14370 | 13895 | 14901 | 5.3 | 3.3 | 0.9 |
| កម្មករសំណង់មិនជំនាញ | 13184 | 13336 | 15349 | 17365 | 16664 | 14796 | 17533 | 20371 | 18082 | 26.2 | 6.2 | 8.5 |
| កម្មករសំណង់មានជំនាញ | 15442 | 17420 | 18624 | - | 21716 | 21924 | 23014 | 24951 | 25578 | 20.0 | 19.7 | 17.8 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI. November 2015 data are not available.

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ**...

ថ្ងៃទី ២៨ កុម្ភៈ ក្រុងភ្នំពេញ

**សិក្ខាសាលាផ្ដួចផ្ដើមគំនិតអប់រំ STEM របស់អ្នកដឹកនាំវ័យក្មេងនៅអាស៊ីអាគ្នេយ៍** (YSEALI)៖ សិក្ខាសាលានេះ ជាគំនិតផ្ដួចផ្ដើមរបស់ ក្រសួងការបរទេសសហរដ្ឋអាមេរិក ដើម្បីពង្រឹងការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងការកសាងបណ្ដាញនៅអាស៊ីអាគ្នេយ៍។ បុរសនារីវ័យក្មេងប្រមាណ ១០០នាក់ មកពី បណ្ដាប្រទេសអាស៊ាន បានចូលរួមក្នុងសិក្ខាសាលានេះ។ នាយកប្រតិបត្តិវិទ្យាស្ថាន CDRI បានថ្លែងសុន្ទរកថាបំផុសគំនិតដ៏សំខាន់មួយស្ដីពី ផ្លូវអាជីពផ្នែក STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា) ។

ថ្ងៃទី២៨ កុម្ភៈ ២មីនា ក្រុងភ្នំពេញ

**សន្និបាតប្រចាំឆ្នាំ២០១៨ នៅ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖** ព្រឹត្តិការណ៍នេះជាឱកាសល្អមួយសម្រាប់នាយកប្រតិបត្តិនៃ CDRI ដើម្បីបានដឹងពី គោលដៅជាយុទ្ធសាស្ត្ររបស់ក្រសួងសម្រាប់ឆ្នាំ២០១៨។ គំនិតផ្ដួចផ្ដើមថ្មីមួយ គឺការបង្កើតវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ (NIDIR) ដើម្បីបម្រើការជា មជ្ឈមណ្ឌលផ្ដល់គំនិត និងបណ្ដុះបណ្ដាល សម្រាប់បុគ្គលិកក្រសួងការបរទេស។ វិទ្យាស្ថាន CDRI បានទទួលការអញ្ជើញឲ្យផ្ដល់ជំនួយគាំទ្រផ្នែកបច្ចេកទេស និងជួយកសាងសមត្ថភាព សម្រាប់ការស្រាវជ្រាវ និងការកសាងបណ្ណាល័យនៅ NIDIR។

ថ្ងៃទី១៤ មីនា ក្រុងភ្នំពេញ

**កិច្ចប្រជុំពេញអង្គប្រចាំឆ្នាំនៃក្រុមប្រឹក្សាភិបាល CDRI៖** បណ្ឌិត ម៉ី កល្យាណ បានបន្តតំណែងពី បណ្ឌិត សុក ស៊ីផាន់ណា ក្នុងឋានៈជា ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន CDRI។ ក្រុមប្រឹក្សាភិបាល បានអរគុណ បណ្ឌិត សុក ស៊ីផាន់ណា ចំពោះការគាំទ្រយ៉ាងខ្លាំងក្លា និងការប្ដេជ្ញាចិត្តយ៉ាងមុតមាំជួយដល់ CDRI។

ថ្ងៃទី១៥ មីនា ក្រុងភ្នំពេញ

**សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៨៖** វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ឧស្សាហូបនីយកម្ម កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជា៖ ជាថ្មីម្ដងទៀត សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាអធិបតី និងសុន្ទរកថាគន្លឹះបើកសន្និសីទ។ តាមរយៈ ការស្រាវជ្រាវជាយុទ្ធសាស្ត្រ និងការសន្ទនាជាមួយក្រសួងសំខាន់ៗ សាកលវិទ្យាល័យក្នុងស្រុក ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ និងវិស័យឯកជន វិទ្យាស្ថាន CDRI បានចូលរួមចំណែកជំរុញរបៀបវារៈជាតិផ្នែក វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងលក្ខណៈជាជម្រើសដ៏ល្អ សម្រាប់កំណើនឧស្សាហកម្មថែមទៀត។ បទបង្ហាញ និងការពិភាក្សាផ្សេងៗនៅក្នុងសន្និសីទ ក៏ដូចជា កម្រងសព្វគ្រប់នៃជម្រើសផ្នែកគោលនយោបាយ បានយកមកសង្ខេប និងចុះក្នុងអត្ថបទសង្ខេបចក្ខុវិស័យ ដែលអាចរកបាននៅ www.cdri.org.kh ។

ថ្ងៃទី២៦ មីនា ក្រុងគុនមីង ខេត្តយូណាន ប្រទេសចិន

**សិក្ខាសាលាអន្តរជាតិស្ដីពីសហប្រតិបត្តិការមេគង្គឡានឆាង** (LMC) - **ផ្លូវដើរទៅមុខ៖** សិក្ខាសាលានេះរៀបចំឡើងដោយ មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ាន នៅសាកលវិទ្យាល័យគុនមីងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានប្រមូលផ្ដុំអ្នកតំណាង និងអ្នកស្រាវជ្រាវជាន់ខ្ពស់មកពី ក្រុមផ្ដល់គំនិតនៅតាម ៦ប្រទេសសមាជិកក្នុងតំបន់មេគង្គក្រោម (LMC) ដើម្បីពិភាក្សា និងកំណត់របៀបវារៈស្រាវជ្រាវជាយុទ្ធសាស្ត្រ និង វេទិកាសមស្របសម្រាប់ការសន្ទនាផ្នែកគោលនយោបាយ។ នាយកប្រតិបត្តិវិទ្យាស្ថាន CDRI បានផ្ដល់នូវសារសំខាន់ៗមួយចំនួនស្ដីពី តួនាទីនៃក្រុមផ្ដល់គំនិតនានា។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

ក្រុមស្រាវជ្រាវកំពុងអនុវត្តន៍ ៥គម្រោង។ អង្កេតចុងក្រោយសម្រាប់គម្រោង *ការសាកល្បងគំរូ (model) ផ្សព្វផ្សាយកសិកម្មបែបថ្មីនៅកម្ពុជា* ដែលផ្ដល់ជំនួយឧបត្ថម្ភដោយ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) បានចាប់ផ្ដើមក្នុងខែមីនា ហើយរំពឹងថានឹងចប់សព្វគ្រប់នៅដើមខែមេសា។ សម្រាប់គម្រោងទទួលបានជំនួយឧបត្ថម្ភពី ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ស្ដីពី *ការអនុវត្តស្ដង់ដាសុវត្ថិភាពក្នុងផលិតកម្មបន្លែនៅកម្ពុជា: ករណីការដាំបន្លែ* កំពុងមានដំណើរការល្អ ដោយការបញ្ចូលទិន្នន័យបានចប់អស់ ហើយការវិភាគ និងសរសេររបាយការណ៍ ក៏បានចាប់ផ្ដើម។ គម្រោងថ្មី ២ បានចាប់អនុវត្តទៅមុខដែរ គឺគម្រោងទី១ *ការផលិតប្រចាំត្រីមាសនូវ ព្រឹត្តិប័ត្រព័ត៌មានបច្ចេកវិទ្យាកសិកម្ម* ដែលទទួលជំនួយគាំទ្រពី Swisscontact Cambodia និង គម្រោងទី២ ស្ដីពី *ការវិភាគពីខ្សែសង្វាក់តម្លៃផ្លែស្វាយ* ដែលទទួលបានមូលនិធិពី Sida។ ព្រឹត្តិប័ត្រព័ត៌មាននេះ មានគោលដៅ កាត់បន្ថយគម្លាតទំនាក់ទំនងរវាងកសិករ អ្នកស្រាវជ្រាវ អ្នកកសាងគោលនយោបាយ និងអ្នកអនុវត្ត ដោយផ្ដល់ព័ត៌មានទាន់ពេលនិងអាចរកបានស្ដីពី បច្ចេកវិទ្យាកសិកម្មថ្មីៗ ព័ត៌មានផ្សេងៗ របៀបរបបអនុវត្តល្អៗ និងប្រធានបទពាក់ព័ន្ធនានា។ ស្របតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២៥ ការវិភាគខ្សែសង្វាក់តម្លៃមានគោលដៅបង្ហាញជាក់លាក់នូវ ខ្សែសង្វាក់តម្លៃផ្លែស្វាយនៅកម្ពុជា ដោយសង្កត់ធ្ងន់លើទំនាក់ទំនងរវាង តួអង្គសំខាន់ៗក្នុងខ្សែសង្វាក់នេះ និងសហគ្រិនភាពរបស់ពួកគេ។

## ផ្នែកសេដ្ឋកិច្ច

ផ្នែកនេះ បានទទួលអំណោយមូលនិធិចំនួន ៣ ពីដៃគូស្រាវជ្រាវផ្សេងៗ។ ផ្នែកសេដ្ឋកិច្ចទទួលបានអំណោយមូលនិធិពីក្រសួងការបរទេសនៃប្រទេសចិន ក្នុងក្របខ័ណ្ឌនៃ *កិច្ចសន្ទនានិងសហប្រតិបត្តិការនៅតំបន់ទន្លេមេគង្គ-ឡានឆាង* ដើម្បីដឹកនាំកម្មវិធីស្រាវជ្រាវថ្នាក់តំបន់មួយស្តីពី ការលើកកម្ពស់ការស្រាវជ្រាវនិងកិច្ចសន្ទនាផ្នែកគោលនយោបាយ រវាងប្រទេសចិន-តំបន់មេគង្គពីខែមីនា២០១៨ដល់កុម្ភៈ២០២០។កម្មវិធីនេះមានសមាសភាគ ២ គឺការស្រាវជ្រាវ និងកិច្ចសន្ទនាផ្នែកគោលនយោបាយ។ ការស្រាវជ្រាវសំដៅផ្តល់ភស្តុតាងជាក់ស្តែង និងជួយមតិផ្នែកគោលនយោបាយដល់ កិច្ចសន្ទនានៅតំបន់ទន្លេមេគង្គ-ឡានឆាង ដោយផ្តោតជាពិសេសលើ ពាណិជ្ជកម្មផ្នែកកសិកម្មរវាងប្រទេសចិន នឹងបណ្តាប្រទេសនៅតំបន់មេគង្គ។កិច្ចសន្ទនាផ្នែកគោលនយោបាយរួមមាន សិក្ខាសាលាបច្ចេកទេស និងសន្និសីទថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ។ ផ្នែកនេះក៏ទទួលបានអំណោយមូលនិធិតូចមួយពី ភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច ដើម្បីធ្វើការសិក្សាលើ *ចំណាកស្រុក ការផ្ញើរប្រាក់ទៅផ្ទះ និងការចូលរៀនសាលានៃកុមារនៅតាមជនបទកម្ពុជា*។ អ្នកដឹកនាំ និងសមាជិកគម្រោង បានទទួលការអញ្ជើញឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអ៊ិនធើណិតផ្តល់ដោយសាកលវិទ្យាល័យ Laval នៅប្រទេសកាណាដា ស្តីពី ការវិភាគពីផលប៉ះពាល់ផ្នែកគោលនយោបាយ។គម្រោងស្តីពី *ការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យនៃ វិធានការមិនមែនពន្ធគយ នៅកម្ពុជា* ដែលទទួលមូលនិធិពី វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់អាស៊ាន និងអាស៊ីខាងកើត (ERIA) បានចាប់អនុវត្តនៅខែមីនា ២០១៨។ ក្រុមស្រាវជ្រាវបានចូលរួមក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអ៊ិនធើណិតស្តីពី វិធានការមិនមែនពន្ធគយក្នុងអាស៊ាននៅដំណាក់កាលទី៣ ក្នុងខេត្តភូកេត ប្រទេសថៃ នៅខែមីនា ២០១៨។ ផ្នែកនេះក៏បានសហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និងនយោបាយពិភពលោក នៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមនៃប្រទេសចិន (CASS) ដើម្បីធ្វើការសិក្សាពី *សហប្រតិបត្តិការនៅតំបន់មេគង្គ-ឡានឆាង និងការអភិវឌ្ឍខ្សែសង្វាក់ផលិតកម្មវាយនភ័ណ្ឌ និងសម្លៀកបំពាក់នៅក្នុងតំបន់*។ របាយការណ៍ស្រាវជ្រាវរបស់ប្រទេសកម្ពុជា នេះ CASS នឹងយកទៅបញ្ចូលគ្នាជាមួយរបាយការណ៍របស់ប្រទេសផ្សេងទៀត។

## ផ្នែកអប់រំ

សន្និសីទ DRF លើកទី១០ បានរៀបចំឡើងនៅថ្ងៃទី ១២ កុម្ភៈ។ ព្រឹត្តិការណ៍នៅឆ្នាំនេះទទួលបានជំនួយគាំទ្រពី ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត(Sida) និងគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុកជាច្រើន។ សន្និសីទនេះមានប្រធានបទស្តីពី ការអភិវឌ្ឍការអប់រំថ្នាក់ក្រោយមធ្យមសិក្សា តាមរយៈការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើន។

ក្រុមស្រាវជ្រាវក្នុងផ្នែកនេះបានពង្រីក ការសិក្សាស្រាវជ្រាវពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា (STEM) ដោយធ្វើអង្កេតលើសិស្សវិទ្យាល័យជាង ២.000នាក់ ក្នុងទូទាំងប្រទេស ដើម្បីស្វែងយល់ពីជម្រើសរបស់សិស្សក្នុងការចូលរៀនខាងផ្នែកវិទ្យាសាស្ត្រ ធៀបនឹងខាងផ្នែកវិទ្យាសាស្ត្រសង្គម។ ក្រុមស្រាវជ្រាវក៏បានចាប់អនុវត្ត គម្រោងថ្មីមួយដែលពិនិត្យពីអត្តសញ្ញាណផ្នែកសិក្សាអប់រំ និងគណនេយ្យភាពនៃឧត្តមសិក្សានៅកម្ពុជា។ វេទិកាអ្នកហាត់ការលើកទី២ បានរៀបចំឡើងនៅថ្ងៃទី១២ មករា ដែលបើកឱកាសឲ្យអ្នកហាត់ការនានា ធ្វើបទបង្ហាញពីលទ្ធផលរកឃើញក្នុងគម្រោងខ្លួនបានចូលរួម។

ការថយទៅពិភាក្សាពី វិស័យសិល្បៈនៅក្នុងការអប់រំផ្នែកវិទ្យាសាស្ត្រ បានធ្វើឡើងនៅថ្ងៃទី ៤-៥ មករា នៅក្រុងកែប ដើម្បីផ្តល់នូវ វេទិកាមួយសម្រាប់ឲ្យអ្នកកសាងគោលនយោបាយផ្នែកអប់រំ ដៃគូអភិវឌ្ឍន៍ អ្នកសិក្សាជ្រៅជ្រះ អ្នកស្រាវជ្រាវ ផ្លាស់ប្តូរគំនិតគ្នាពី តម្លៃនៃសិល្បៈជាទូទៅ និងនៅក្នុងការអប់រំផ្នែកវិទ្យាសាស្ត្រនៅកម្ពុជា។

បណ្ឌិត សុង សុភ័ក្រ បានដឹកនាំគណៈប្រតិភូទៅក្រុង Shenzhen ប្រទេសចិន ដើម្បីសិក្សាពីការអភិវឌ្ឍ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET)។ សមាសភាពគណៈប្រតិភូ រួមមាន តំណាងមកពីខាងរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា។ ទស្សនកិច្ចនេះជាផ្នែកមួយនៃការសិក្សាប្រៀបធៀបប្រព័ន្ធ TVET ក្នុង ៤ប្រទេសគឺ កម្ពុជា ចិន កូរ៉េខាងត្បូង និង ស្វីស ដែលផ្តល់មូលនិធិដោយ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC)។

## ផ្នែកបរិស្ថាន

គម្រោងរយៈពេលពីរឆ្នាំ ស្តីពី *ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីលើការធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា* ដែលទទួលបានមូលនិធិពី មូលនិធិសហប្រជាជាតិដើម្បីប្រជាធិបតេយ្យ (UNDEF) កំពុងជឿនលឿនទៅមុខយ៉ាងល្អ។ អ្នកចូលរួមក្នុងគម្រោងបានទទួលអត្ថប្រយោជន៍ពី ទស្សនកិច្ចស្វែងយល់អំពីគម្រោងបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ផ្អែកលើសហគមន៍ ដោយមានការបង្កើត បណ្តាញគាំទ្រស្ត្រី ចំនួន ១០ នៅកម្រិតឃុំ។ បណ្តាញទាំងនេះទទួលបានការជួយសម្របសម្រួលពី អង្គការមិនមែនរដ្ឋាភិបាលជាដៃគូនៅតាមមូលដ្ឋាន ហើយបណ្តាញនីមួយៗ រួមមាន ប្រធានក្រុម អនុប្រធានក្រុម ហិរញ្ញិក និងសមាជិកក្រុមនានា។ ពួកគេរៀបចំការប្រជុំប្រចាំខែ ដើម្បីចែករំលែកព័ត៌មានអាចទុកចិត្តបានលើការប្រែប្រួលអាកាសធាតុ និងដើម្បីកសាងជំនាញ (ការធ្វើទំនាក់ទំនង ការសម្របសម្រួល ការរៀបចំ ការរាយការណ៍) ចំណេះដឹង និងទំនុកចិត្តរបស់ខ្លួន (ការចូលរួមផ្នែកសង្គមកិច្ច)។

គម្រោងទទួលបានមូលនិធិពី Sida ស្តីពី ការបន្សុំានឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃ គ្រោះមហន្តរាយ កំពុងស្ថិតក្នុងដំណាក់កាលវិភាគទិន្នន័យ និងការសរសេររបាយការណ៍។ សម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ និងការពិភាក្សាតាមក្រុមស្នូល សម្រាប់គម្រោងស្តីពី *ចម្លើយតបរបស់មនុស្សទៅនឹង ការផ្លាស់ប្តូរបរិស្ថានក្នុងអាងទន្លេមេគង្គក្រោម* បានអនុវត្តឡើងនៅតាមភូមិគោលដៅក្នុងខេត្តកំពង់ចាម ព្រៃវែង តាកែវ កណ្តាល កំពង់ស្ពឺ ហើយកំណត់ត្រាផ្សេងៗនៃការចុះសិក្សាដល់កន្លែង ក៏បានរៀបចំឡើងដែរ។

នាពេលថ្មីៗ ផ្នែកនេះ បានចុះកិច្ចសន្យាសម្រាប់គម្រោងថ្មី២ ដែលកំពុងអនុវត្តទៅមុខជាបណ្តើរៗ។សកម្មភាពក្នុងគម្រោងស្តីពី *ការធ្វើកសិកម្មតាមកិច្ចសន្យា ក្នុងតំបន់មេគង្គ-ឡានឆាង* រួមមាន ការរៀបចំការប្រជុំពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធនានា ការជ្រើសរើសដៃគូសហការនៅក្នុងតំបន់ និងការរៀបចំសិក្ខាសាលាចាប់ផ្តើមគម្រោងកម្រិតតំបន់។ សម្រាប់គម្រោងទី២ ស្តីពី *ផលប៉ះពាល់នៃ កម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ យេនឌ័រ និងសិទ្ធិមនុស្ស* គឺក្រុមស្រាវជ្រាវកំពុងបញ្ចប់ក្របខ័ណ្ឌទស្សនាទានតាមការពិភាក្សាជាមួយ ក្រសួងអភិវឌ្ឍន៍ជនបទ និងកម្មវិធីអភិវឌ្ឍនៃអង្គការសហប្រជាជាតិ (UNDP) កម្ពុជា។

## ផ្នែកអភិបាលកិច្ច

ផ្នែកនេះ បានបង្ហើយអង្កេតធំមួយដែលតំណាងឲ្យទូទាំងប្រទេស សម្រាប់គម្រោងស្តីពី *មនុស្សជំនាន់ថ្មី៖ ការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍ និងនយោបាយ*។ នេះជាអង្កេតគ្រប់ជ្រុងជ្រោយលើកទី១ ប្រភេទនេះ ដែលបានរចនារៀបចំឡើង ដើម្បីបង្កើនការយល់ដឹងដ៏សំខាន់ស្តីពី ការយល់ឃើញរបស់យុវវ័យលើការអភិវឌ្ឍនិងនយោបាយ ទំនុកចិត្តនិងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ហើយនិងបំណងចង់បាននិងការរំពឹងទុកទៅអនាគត។ អង្កេតអនុវត្តឡើងតាមរយៈ សម្ភាសន៍ទល់មុខគ្នានៅក្នុងផ្ទះរបស់អ្នកឆ្លើយសំណួរ ដែលត្រូវបានជ្រើសរើសដោយចៃដន្យ ដោយប្រើវិធីជ្រើសរើសសំណាកមានច្រើនដំណាក់ច្រើនស្រទាប់។ គ្រោងសំណាក រួមមាន ១០១ភូមិ ក្នុង ៦ខេត្ត/ក្រុង គឺ បាត់ដំបង កំពត ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម និង ភ្នំពេញ។ ក្រុមស្រាវជ្រាវបានជ្រើសរើសអ្នកមានបទពិសោធន៍ ១០នាក់ ឲ្យចុះធ្វើអង្កេតដោយប្រើកម្មវិធីទូរស័ព្ទនិងកុំព្យូទ័រខ្នាតតូច (tablet computers) ជាជាង បញ្ជីសំនួរលើក្រដាស។ ការប្រមូលទិន្នន័យ និងវិភាគទិន្នន័យបានរួចរាល់អស់ក្នុងខែមករា ២០១៨ ហើយឯកសារពិភាក្សាមួយក៏បានរួចរាល់ដែរ សម្រាប់ការបោះពុម្ពនិងផ្សព្វផ្សាយ ។

ការងារលើគម្រោងស្តីពី *អភិបាលកិច្ចល្អនូវទឹកទន្លេមេគង្គ* បានចប់អស់ដោយជោគជ័យ។ ក្រុមស្រាវជ្រាវបានរៀបចំជាមួយ គូអង្គសំខាន់ៗមួយចំនួននូវ សិក្ខាសាលាផ្សព្វផ្សាយមួយ ស្តីពី ការអភិវឌ្ឍវារីអគ្គិសនីនៅកម្ពុជា និងអភិបាលកិច្ចទឹកទន្លេមេគង្គ នៅថ្ងៃទី១៤ កុម្ភៈ។ ការពិភាក្សា និងព័ត៌មានត្រឡប់ នៅក្នុងសិក្ខាសាលា បានយកមកដាក់បញ្ចូលក្នុងរបាយការណ៍ពីរដែលចងក្រងរួចរាល់ហើយស្តីពី "ការតាំងទីលំនៅជាថ្មី និងការចិញ្ចឹមជីវិតប្រកបដោយចីរភាព៖ ករណីទំនប់សេសានក្រោម២" និង "ការពិចារណាពីយេនឌ័រ ក្នុងដំណើរការតាំងទីលំនៅជាថ្មី៖ ករណីទំនប់សេសានក្រោម២"។ វេទិកាអង្គការមិនមែនរដ្ឋាភិបាលសម្រាប់កម្ពុជា ដែលជាដៃគូអនុវត្តគម្រោង បានផ្តល់ឯកសារវីឌីអូមួយស្តីពី ទំនប់សេសានក្រោម២ ហើយសាកលវិទ្យាល័យជាតិសិង្ហបុរី បានបោះពុម្ពផ្សាយរបាយការណ៍មួយលើ ផលប៉ះពាល់សង្គមនៃវារីអគ្គិសនីទន្លេមេគង្គ៖ ភស្តុតាងបានពីទំនប់សេសានក្រោម២ នៅកម្ពុជា។

## ផ្នែកសុខាភិបាល

ផ្នែកសុខាភិបាល រួមសហការជាដៃគូជាមួយ មហាវិទ្យាល័យវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) កំពុងអនុវត្តគម្រោងស្រាវជ្រាវសម្រាប់សកម្មភាព ហៅថា ការពង្រឹងវិជ្ជាជីវៈគ្រូពេទ្យ តាមរយៈ ការពង្រឹងចំណេះដឹង និងឥរិយាបថលើក្រមសីលធម៌គ្រូពេទ្យ។ គម្រោងនេះ ផ្តល់មូលនិធិដោយ GlaxoSmithKline។ សកម្មភាពជាច្រើនក្នុងបីខែចុងក្រោយផ្តោតលើ ការប្រមូលទិន្នន័យ ការសំអាតទិន្នន័យ និងការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ។ ការប្រមូលទិន្នន័យ រួមមាន ការធ្វើអង្កេតលើនិស្សិតពេទ្យ ២៤០នាក់ និងការធ្វើសម្ភាសន៍ស៊ីជំម្រៅជាមួយសាស្ត្រាចារ្យ ២៥នាក់ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ។ ទិន្នន័យអង្កេតបែបបរិមាណវិស័យ បានយកមកវិភាគដោយប្រើកម្មវិធីកុំព្យូទ័រ SPSS ហើយ ព័ត៌មានបែបគុណវិស័យតាមប្រធានបទ បានមកពីសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ បានយកមកវិភាគដោយប្រើកម្មវិធីកុំព្យូទ័រ NVivo។ អ្នកស្រាវជ្រាវនៅ CDRI និង UHS បានជួបគ្នាជាទៀងទាត់ ដើម្បីពិភាក្សាពីទិន្នន័យ និងការបកស្រាយលទ្ធផល។ ផ្នែកនេះកំពុងសរសេររបាយការណ៍មួយ សម្រាប់បោះពុម្ពផ្សាយជា ឯកសារពិភាក្សា។ លទ្ធផលរកឃើញ នឹងយកទៅចែករំលែកក្នុង សិក្ខាសាលាផ្សព្វផ្សាយមួយ នៅខែឧសភា ដែលគ្រោងមានការចូលរួមពីអ្នកវិជ្ជាជីវៈខាងសុខាភិបាល ជាង៨០នាក់ មកពី គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ក្រសួងសុខាភិបាល វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើការក្នុងវិស័យសុខាភិបាល។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

ពីខែមករា ដល់ មីនា ២០១៨ ក្រុមអ្នកស្រាវជ្រាវ នាយកផ្នែកស្រាវជ្រាវ និង នាយកប្រតិបត្តិ បានតំណាងឲ្យវិទ្យាស្ថាន CDRI ក្នុងព្រឹត្តិការណ៍ដូចតទៅ៖

ថ្ងៃទី ៤-៥ មករា ក្រុងកែប

**ការថយទៅពិភាក្សាពី វិទ្យាសាស្ត្រអប់រំ៖** ការស្រាវជ្រាវពីវិទ្យាសាស្ត្របង្រៀន និងរៀនសូត្រ បង្ហាញថា ការដាក់បញ្ចូលសិល្បៈទៅក្នុងកម្មវិធីសិក្សា អាចជួយបំផុសភាពច្នៃប្រឌិត ការចង់ចេះចង់ដឹង និងចំណូលចិត្តផ្នែកវិទ្យាសាស្ត្ររបស់អ្នករៀនសូត្រ។ ការថយទៅពិភាក្សាគិតគូរនេះ សំដៅប្រមូលមកជួបជុំគ្នានូវគ្រូបង្រៀនក្នុងវិស័យសាធាណៈ និងឯកជន ព្រមទាំងសាស្ត្រាចារ្យផ្នែកសិល្បៈ និងវិទ្យាសាស្ត្រ នៅតាមសាកលវិទ្យាល័យ ដើម្បីស្វែងរកជម្រើសគោលនយោបាយប្រកបដោយនវានុវត្តន៍ និងបង្កើនប្រសិទ្ធភាពនៃ កម្មវិធីសិក្សាផ្នែកវិទ្យាសាស្ត្រនៅតាមសាលារៀនកម្ពុជា តាមរយៈការដាក់បញ្ចូលសិល្បៈ ដើម្បីធ្វើជាផ្លូវឈានទៅមុខក្នុងការរៀនសូត្រ។

ថ្ងៃទី ៨ កុម្ភៈ ក្រុងភ្នំពេញ

**សិក្ខាសាលាពិគ្រោះយោបល់លើ យុទ្ធសាស្ត្រស្រាវជ្រាវឆ្នាំ២០១៦-២១ របស់វិទ្យាស្ថាន** CDRI៖ ព្រឹត្តិការណ៍នេះជាចំណុចកំពូលនៃ កិច្ចពិភាក្សា និងការប្រឹក្សាជាច្រើនវគ្គ ដែលបាននាំមកជួបជុំគ្នានូវ អ្នកកសាងគោលនយោបាយ និងអ្នកអនុវត្តជាក់ស្ដែង ជាង៤០ មកពីខាង រដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីពិភាក្សា និងកែសម្រួលបន្ថែមលើប្រធានបទស្រាវជ្រាវ ដែលបានដាក់ស្នើឡើង សម្រាប់ផែនការ៥ឆ្នាំ។ ការផ្ដល់មតិយោបល់ផ្សេងៗ បានយកទៅដាក់បញ្ចូលក្នុង យុទ្ធសាស្ត្រស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ដែលក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន បានអនុម័តយល់ព្រមក្នុងកិច្ចប្រជុំពេញអង្គ កាលពីខែមីនា។

ថ្ងៃទី ១២ កុម្ភៈ ក្រុងភ្នំពេញ

**សន្និសីទប្រចាំឆ្នាំនៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា ស្ដីពី ការអភិវឌ្ឍឧត្ដមសិក្សា តាមរយៈការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន៖** សន្និសីទនេះរៀបចំឡើងដោយ វិទ្យាស្ថាន CDRI និង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងមានអ្នកចូលរួមប្រមាណ ១៥០នាក់ មកពីស្ថាប័នផ្សេងៗដែលធ្វើការដោយផ្ទាល់ ឬដោយប្រយោលខាងផ្នែកឧត្ដមសិក្សា និង ការអប់រំបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដើម្បីពិភាក្សាគ្នាលើបញ្ហាស្នូល ៣ គឺ ១) ការអភិវឌ្ឍឧត្ដមសិក្សាតាមទស្សនវិស័យក្នុងតំបន់ ២) អន្តរជាតូបនីយកម្មឧត្ដមសិក្សា និងការកែលំអគុណភាព ៣) ភាពជាដៃគូរវាងវិស័យសាធារណៈ នឹងឯកជន ដើម្បីលើកកម្ពស់ TVET ឲ្យក្លាយជាជម្រើសដ៏មានតម្លៃសម្រាប់អាជីព។

ថ្ងៃទី ២១កុម្ភៈ ក្រុងភ្នំពេញ

**កិច្ចប្រជុំសហប្រតិបត្តិការមេគង្គ-ឡានឆាង** (LMC)៖ តំណាងមកពីក្រសួង និងក្រុមផ្ដល់គំនិតនានា បានចូលរួមក្នុងការប្រជុំមួយ រៀបចំឡើងដោយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចែករំលែកព័ត៌មានស្ដីពី សិទ្ធិអាចទទួលបាន និងដំណើរការដាក់ពាក្យសុំ មូលនិធិសម្រាប់ការស្រាវជ្រាវ ក្នុងកម្មវិធី MLC។ បន្ទាប់មក វិទ្យាស្ថាន CDRI បានដាក់សំណើស្រាវជ្រាវពីរ ដែលក្រោយមកទៀតទទួលបានមូលនិធិអំណោយ ១លានដុល្លារ។

*តទៅទំព័រ ២១*

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី២២ លេខ១ ខែមីនា ឆ្នាំ២០១៨

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក្ដី។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ពផ្សាយ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ +៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ 🖷 +៨៥៥២៣៨៨០៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសម្រួលៈ យូ សិទ្ធិរិទ្ធ
កែសម្រួលផលិតកម្មៈ អ៊ុំ ចាន់ថា

សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៨ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh